*វិធានជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងវិស័យ*
*យុត្តិធម៌យុវជន ឆ្នាំ ១៩៨៥*

*មាតិកា*

*ផ្នែកទី១ គោលការណ៍ទូទៅ*.................................................................
*ផ្នែកទី២ ការស៊ើបអង្កេត និងការចោទប្រកាន់*.............................................
*ផ្នែកទី៣ ការវិនិច្ឆ័យ និងសំរេចសេចក្តី*.....................................................
*ផ្នែកទី៤ ការគ្រប់គ្រងក្រៅស្ថាប័ន* ...........................................................
*ផ្នែកទី៥ ការគ្រប់គ្រងក្នុងស្ថាប័ន*.............................................................
*ផ្នែកទី៦ ការស្រាវជ្រាវ ការធ្វើផែនការ ការកំណត់គោលនយោបាយ និង ការវាយតំលៃ*..........................................................................................................

*វិធានជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងវិស័យ*
*យុត្តិធម៌យុវជន ឆ្នាំ ១៩៨៥*

*បញ្ញត្តិ ក្រុងប៉េកាំង*

អនុម័តសេចក្ដីសំរេចរបស់មហាសន្និបាតលេខ ៤០/៣៣ ចុះថ្ងៃទី ២៩ វិច្ឆិកា ១៩៨៥

ផ្នែកទី ១

*គោលការណ៍ទូទៅ*

*១. ទស្សនៈជាមូលដ្ឋាន*

*១.១. រដ្ឋជាសមាជិកត្រូវប្រឹងប្រែងធ្វើឱ្យបានចំរើនសុខមាលភាពរបស់យុវជន និង គ្រួសាររបស់គេស្របតាម ផលប្រយោជន៍ទូទៅនៃរដ្ឋនីមួយៗ ។*

*១.២. រដ្ឋជាសមាជិកត្រូវខ្នះខ្នែងបង្កើតលក្ខខ័ណ្ឌនានាដែលនឹងធានាដល់យុវជនឱ្យ មានជីវិតមានន័យនៅក្នុង*
*សហគមន៍ ដែលនឹងជំរុញដំណើរការមួយនៃការចំរើនលូតលាស់ផ្ទាល់ខ្លួន និង ការអប់រំឱ្យរួចផុតពី ឧក្រិដ្ឋកម្ម និង ទោសកម្មដែលអាចធ្វើទៅបាន ដែលនៅក្នុង អំឡុងពេល នៃជីវិតនោះយុវជនងាយនឹង ទទួលអាកប្បកិរិយាខុសពីធម្មតា ។*

*១.៣. ត្រូវយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ដល់វិធានការជាវិជ្ជមានដែលពាក់ព័ន្ធនឹង ការប្រមូលផ្ដុំធនធាន ទាំងអស់ដែលមាន រួមមានគ្រួសារអ្នកស្ម័គ្រចិត្ត និងក្រុម ផ្សេងទៀតរបស់សហគមន៍ ព្រមទាំង សាលារៀន និង ស្ថាប័នផ្សេងទៀតរបស់ សហគមន៍ក្នុងគោលបំណងលើកស្ទួយសុខមាលភាពយុវជន ដើម្បីកាត់បន្ថយ សេចក្ដីត្រូវការអន្តរាគមន៍ពីច្បាប់ និងក្នុងគោលបំណងចាត់ការយុវជនដែលធ្វើ ផ្ទុយនឹង ច្បាប់ ដោយមានប្រសិទ្ធិភាពដោយយុត្តិធម៌ និងក្នុងភាពជាមនុស្ស ។*

*១.៤. យុត្តិធម៌យុវជនត្រូវបានបង្កើតឡើងជាផ្នែកផ្សំមួយនៃដំណើរការអភិវឌ្ឍន៍ជាតិ របស់ប្រទេសនិមួយៗ នៅ ក្នុងក្របខ័ណ្ឌទូលំទូលាយនៃយុត្តិធម៌សង្គមសំរាប់យុវ ជនទាំងអស់ ដូច្នេះទន្ទឹមគ្នានេះរួមចំណែកក្នុងការ ការពារមនុស្សក្មេង និងការ រក្សាសណ្ដាប់ធ្នាប់សុខសាន្តនៅក្នុងសង្គម ។*

*១.៥. វិធានទាំងនេះត្រូវអនុវត្តនៅក្នុងបរិបទនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច សង្គម និង វប្បធម៌ ដែលមាននៅក្នុងរដ្ឋជា សមាជិកនីមួយៗ ។*

១.៦. សេវាកម្មផ្នែកយុត្តិធម៌យុវជនត្រូវតែបានបង្កើតឡើងដោយមានបែបផែន និងសំរបសំរួលក្នុងគោលបំណង លើកស្ទួយ និងទ្រទ្រង់សមត្ថភាពរបស់បុគ្គលដែលពាក់ព័ន្ធនៅក្នុងសេវាកម្មនោះរួមមានវិធីផ្លូវដោះស្រាយ និង ឥរិយាបថរបស់គេ ។

សេចក្តីអធិប្បាយ

ទស្សនៈមូលដ្ឋានទូលំទូលាយទាំងនេះបានដល់គោលនយោបាយសង្គមទូលំទូលាយជាទូទៅ ហើយមានគោលដៅ លើកស្ទួយសុខមាលភាពយុវជនក្នុងកំរិតធំបំផុតដែលអាចធ្វើទៅបាន ដែលនឹងបន្ថយភាពចាំបាច់នៃអន្តរាគមន៍ពីប្រព័ន្ធ យុត្តិធម៌យុវជនឱ្យនៅតិចជាអប្បបរមា ហើយក៏ជួយបន្ថយការប៉ះពាល់ដែលបណ្តាលមកពីការអន្តរាគមន៍ណាមួយ ។ វិធានការយកចិត្តទុកដាក់ចំពោះមនុស្សក្មេងបែបនេះ គឺជាសេចក្តីត្រូវការជាបន្ទាន់នៃគោលនយោបាយដែលកំណត់ឡើង ដើម្បីចៀសវាងមិនចាំបាច់អនុវត្តវិធានទាំងឡាយក្នុងឧបករណ៍នេះ ។ វិធាន ១.១ ដល់ ១.៣ ដៅបញ្ជាក់តួនាទីសំខាន់ នៃគោលនយោបាយសង្គមប្រកបដោយស្ថាបនាសំរាប់យុវជន ជាអាទិ៍ក្នុងការបង្ការឧក្រិដ្ឋកម្ម និង ទោសកម្មរបស់យុវជន។ វិធាន ១.៤ កំណត់ថា យុត្តិធម៌យុវជនជាផ្នែកផ្សំមួយនៃយុត្តិធម៌ សង្គមសំរាប់យុវជន ចំណែកវិធាន ១.៦ សំដៅដល់ភាពចាំបាច់នៃការលើកស្ទួយជាប្រចាំដល់យុត្តិធម៌យុវជន ដោយមិនឱ្យឃ្លាតឆ្ងាយក្រោយការអភិវឌ្ឍន៍គោលនយោបាយ សង្គមជឿនលឿនសំរាប់យុវជនជាទូទៅ និងដោយចាំទុកក្នុងចិត្តនូវសេចក្តីត្រូវការឱ្យមានការកែលំអជាទៀងទាត់នូវ សេវាកម្មរបស់បុគ្គលិក ។ វិធាន ១.៥ យកចិត្តទុកដាក់លើលក្ខខ័ណ្ឌដែលមាននៅក្នុងរដ្ឋជាសមាជិកដែលនឹងបណ្តាលឱ្យ របៀបអនុវត្តវិធានពិសេសណាមួយខុសពីរបៀបដែលប្រកាន់យកនៅក្នុងរដ្ឋដទៃទៀត ។

២. វិសាលភាពនៃវិធាន និង និយមន័យដែលប្រើ

២.១. វិធានជាបទដ្ឋានអប្បបរមាត្រូវអនុវត្តដោយឥតលំអៀងចំពោះយុវជនល្មើស ដោយមិនប្រកាន់ប្រភេទ អ្វីទាំងអស់ ដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ប្រភពសម្បត្តិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃទៀត ។

២.២. សំរាប់គោលបំណងនៃវិធានក្នុងឧបករណ៍នេះ រដ្ឋជាសមាជិកត្រូវអនុវត្តនិយមន័យដូចតទៅនេះក្នុង បែបមួយ ដែលត្រូវគ្នានឹងប្រព័ន្ធច្បាប់ និងគោលគំនិតច្បាប់របស់រដ្ឋនីមួយៗរៀងៗខ្លួន ៖

(ក) យុវជនជាកុមារ ឬ ក្មេងដែលអាចទទួលការចាត់ការនៅក្រោមប្រព័ន្ធច្បាប់នៃរដ្ឋនីមួយៗក្នុង របៀបផ្សេងពីមនុស្សពេញវ័យ ចំពោះបទល្មើសមួយដែលគេបានប្រព្រឹត្ត

(ខ) បទល្មើសជាអាកប្បកិរិយាណាមួយ (ជាអំពើ ឬការមិនបានធ្វើ) ដែលអាចដាក់ទណ្ឌកម្មតាមផ្លូវ ច្បាប់នៅក្រោមប្រព័ន្ធច្បាប់នៃរដ្ឋនីមួយៗ

(គ) យុវទោសករគឺជាកុមារ ឬក្មេងដែលត្រូវបានចោទថាបានប្រព្រឹត្ត ឬដែលបានរកឃើញថាបាន ប្រព្រឹត្តបទល្មើសមួយ ។

២.៣. នៅក្នុងយុត្តាធិការជាតិនីមួយៗ ត្រូវប្រឹងប្រែងបង្កើតសំណុំច្បាប់មួយចំនួន វិធាន និងបញ្ញត្តិដែលអាច អនុវត្តបានចំពោះតែយុវទោសករ ព្រមទាំងស្ថាប័ន និងអង្គការដែលគេប្រគល់មុខងារអោយគ្រប់គ្រង វិស័យយុត្តិធមិយុវជន និង ដែលបង្កើតឡើង ៖

ដើម្បីតម្រូវតាមសេចក្តីត្រូវការខុសៗគ្នារបស់យុវទោសករ ទន្ទឹមគ្នានឹងការការពារសិទ្ធិមូលដ្ឋានរបស់គេ

(ក) ដើម្បីបំពេញសេចក្តីត្រូវការរបស់សង្គម

(ខ) ដើម្បីអនុវត្តវិធានដូចតទៅនេឱ្យបានហ្មត់ចត់ និងត្រឹមត្រូវយុត្តិធមិ ។

សេចក្តីអធិប្បាយ

វិធានជាបទដ្ឋានអប្បបរមាត្រូវបានរៀបចំដោយចេតនា ដើម្បីអោយអាចអនុវត្តបាននៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗ ហើយទន្ទឹមគ្នានេះ ដើម្បីកំណត់បទដ្ឋានជាអប្បបរមាខ្លះសំរាប់គ្រប់គ្រងយុវទោសករ ទៅតាមនិយមន័យណាមួយនៃ ពាក្យយុវជន និងទៅតាមប្រព័ន្ធណាមួយសំរាប់ចាត់ការយុវទោសករ ។ គេត្រូវអនុវត្តវិធានទាំងនេះ ដោយឥតលំអៀង ជានិច្ចដោយមិនបែងចែកប្រភេទណាមួយឡើយ ។

ដូច្នេះវិធាន ២.១ សង្កត់លើសារៈសំខាន់ដែលថា វិធានក្នុងឧបករណ៍នេះត្រូវតែអនុវត្តដោយឥតលំអៀងជានិច្ច និង ដោយគ្មានការបែងចែកប្រភេទអ្វីទាំងអស់ ។ វិធាននេះស្របតាមការកំណត់គោលការណ៍ទី ២ នៃសេចក្តីថ្លែងការណ៍អំពី សិទ្ធិកុមារ ។

វិធាន ២.២ អោយនិយមន័យនៃពាក្យ យុវជន " និង បទល្មើស " ថាជាធាតុផ្សំដើម្បីយល់ពីពាក្យ យុវទោសករ " ដែលកម្មវត្ថុចំបងនៃវិធានជាបទដ្ឋានអប្បបរមា (ប៉ុន្តែសូមមើល

វិធានទី ៣ និង ទី៤) ។ គួរកត់សំគាល់ថា កំរិតអាយុ និងត្រូវអាស្រ័យលើប្រព័ន្ធច្បាប់នីមួយៗ ហើយដូច្នេះត្រូវគោរពយ៉ាងពេញលេញចំពោះប្រព័ន្ធសេដ្ឋកិច្ច សង្គម នយោបាយ វប្បធម៌ និង ច្បាប់របស់រដ្ឋជាសមាជិក ។ ហេតុនេះនាំឱ្យមានអាយុខុសៗគ្នាច្រើនទៅតាមនិយមន័យនៃពាក្យ យុវជន " គឺមានចាប់ពី ៧ឆ្នាំ ដល់ ១៨ឆ្នាំ ឬលើសនេះក៏មាន ។ ការដែលមានអាយុខុសៗគ្នានេះ ហាក់ដូចជាមិនអាចជៀសវាងបាន ទេបើគិតទៅដល់ប្រព័ន្ធច្បាប់របស់ប្រទេសផ្សេងៗគ្នា ហើយមិនបន្ថយឥទ្ធិពលនៃវិធានជាបទដ្ឋានអប្បបរមាទាំងនេះទេ ។

វិធាន ២.៣ ចង់និយាយអំពីភាពចាំបាច់ត្រូវបង្កើតច្បាប់ណាមួយជាក់លាក់របស់ប្រទេសដើម្បីអនុវត្តវិធាន ជាបទដ្ឋានអប្បបរមាឱ្យបានប្រសើរបំផុត ទាំងតាមផ្លូវច្បាប់ទាំងតាមផ្លូវអនុវត្ត ។

៣. ការលាតសន្ធឹងនៃវិធាននៃឧបករណ៍នេះ

៣.១ បញ្ញត្តិដែលពាក់ព័ន្ធទាំងឡាយនៃវិធានទាំងនេះ មិនត្រូវអនុវត្តចំពោះតែយុវទោសករប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវអនុវត្តផងដែរចំពោះយុវជនដែលអាចរងការចាត់ការតាមផ្លូវច្បាប់ ដោយសារការប្រព្រឹត្តអាកប្បកិរិយា ជាក់លាក់ណាមួយ ហើយអាកប្បកិរិយានោះបើសិនជាប្រព្រឹត្តដោយមនុស្សពេញវ័យវិញ គឺមិនអាចផ្តន្ទាទោសបានទេ ។

៣.២ ត្រូវធ្វើកិច្ចប្រឹងប្រែងដើម្បីលាតសន្ធឹងគោលការណ៍ទាំងឡាយ ដែលមាននៅក្នុងវិធានទាំងនេះទៅដល់ យុវជនទាំងអស់ដែលជាប់ពាក់ព័ន្ធនៅក្នុងនីតិវិធីចាត់ការរឿងសុខមាលភាព និងការថែទាំ ។

៣.៣ ត្រូវធ្វើកិច្ចប្រឹងប្រែងដើម្បីលាតសន្ធឹងគោលការណ៍ទាំងឡាយ ដែលមាននៅក្នុងវិធានទាំងនេះទៅ ដល់ជនល្មើសជាមនុស្សពេញវ័យក្មេងៗ ។

សេចក្តីអធិប្បាយ

វិធានទី ៣ លាតសន្ធឹងការការពារដែលផ្តល់ដោយវិធានបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងវិស័យយុត្តិធម៌ យុវជនដើម្បីគ្របដណ្តប់ ៖

(ក) បទល្មើសដែលគេហៅថា "បទល្មើសដោយសារគុណសម្បត្តិរបស់អ្នកប្រព្រឹត្ត " ដែលមានចែងនៅក្នុង ប្រព័ន្ធច្បាប់របស់ប្រទេសផ្សេងៗ ដែលនៅក្នុងនោះវិសាលភាពនៃអាកប្បកិរិយា ដែលត្រូវចាត់ទុកជា បទល្មើសមួយមានទំហំធំសំរាប់

យុវជនជាងសំរាប់មនុស្សពេញវ័យ (ឧទាហរណ៍ ការគេចវេសសាលារៀន ការមិនស្តាប់បង្គាប់សាលារៀន និងគ្រួសារ ការផឹកស្រវឹងនៅទីសាធារណៈ ។ល។) (វិធាន ៣.១)

(ខ) នីតិវិធីចាត់ការពីបញ្ហាសុខមាលភាព និងការថែទាំ (វិធាន ៣.២)

(គ) នីតិវិធីចាត់ការជនល្មើសពេញវ័យ ដែលអាស្រ័យលើកំរិតអាយុ ដែលប្រព័ន្ធច្បាប់នីមួយៗកំណត់ (វិធាន ៣.៣)

ការលាតសន្ធឹងវិធានទាំងនេះដើម្បីគ្របដណ្តប់វិស័យបីទាំងនេះ ហាក់ដូចជាបានផ្តល់ហេតុផលបញ្ជាក់ហើយ ។ វិធាន ៣.១ ផ្តល់ការធានាជាអប្បបរមានៅក្នុងវិស័យទាំងនោះ ហើយវិធាន ៣.២ ត្រូវបានចាត់ទុកថា ជាជំហានគួរឱ្យ ចង់បានឆ្ពោះទៅរកទិសដៅនៃយុត្តិធម៌កាន់តែត្រឹមត្រូវសមរម្យ និងប្រកបដោយក្តីមេត្តាឡើងសំរាប់យុវជនទាំងអស់ ដែលធ្វើផ្ទុយនឹងច្បាប់ ។

## ៤. អាយុដែលមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

៤.១. នៅក្នុងប្រព័ន្ធច្បាប់ទាំងឡាយណា ដែលទទួលស្គាល់គោលគំនិតនៃអាយុដែលមានការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌការចាប់ផ្តើមចូលអាយុនោះ មិនត្រូវកំណត់អាយុនៅទាបពេកទេ ដោយត្រូវគិតដល់ ភាពចាស់ទុំផ្នែកអារម្មណ៍ (ការរំភើប ឬរំជួលចិត្ត) ផ្នែកសតិ និង បញ្ញា ។

### សេចក្តីអធិប្បាយ

អាយុអប្បបរមាដែលមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌខុសគ្នាពីមួយទៅមួយអាស្រ័យលើប្រវត្តិសាស្ត្រ និង វប្បធម៌ ។ គំនិតសម័យទំនើបនឹងពិចារណាថា តើកុមារអាចឈានដល់កំរិតសីលធម៌ និង ចិត្តសាស្ត្រល្មមអោយទទួល ខុសត្រូវផ្នែកព្រហ្មទណ្ឌបាន ឬនៅមានន័យថា កុមារម្នាក់ដោយអាស្រ័យការយល់ដឹង និងការចេះពិចារណាតើគេអាចឱ្យ កុមារនោះទទួលខុសត្រូវចំពោះអាកប្បកិរិយាប្រឆាំងនឹងសង្គមបានដែរឬទេ ។ បើសិនជាអាយុដែលមានការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌត្រូវបានកំណត់ឱ្យទាបពេក ឬបើគ្មានកំណត់អាយុទាបបំផុតសោះទេនោះ កំរិតនៃការទទួលខុសត្រូវនោះ មុខជាគ្មានន័យអ្វីទាំងអស់ ។ ជាទូទៅ មានទំនាក់ទំនងជិតស្និទ្ធិរវាងកំរិតនៃការទទួលខុសត្រូវចំពោះអាកប្បកិរិយាជា ទោសកម្ម ឬព្រហ្ម

ទណ្ឌព្រមទាំងសិទ្ធិ និងការទទួលខុសត្រូវផ្នែកសង្គមដទៃទៀត (ដូចជាស្ថានភាពអាពាហ៍ពិពាហ៍ នីតិភាពផ្នែករដ្ឋប្បវេណី ។ល។)

ដូច្នេះ ត្រូវធ្វើកិច្ចប្រឹងប្រែងដើម្បីព្រមព្រៀងលើកំរិតទាបបំផុតដែលសមរម្យដែលអាចអនុវត្តបានជាអន្តរជាតិ ។

៥. គោលដៅនៃយុត្តិធម៌យុវជន

៥.១. ប្រព័ន្ធយុត្តិធម៌យុវជនត្រូវផ្តោតទៅលើសុខមាលភាពរបស់យុវជន ហើយត្រូវធានាថាប្រតិកម្មណាមួយ ចំពោះយុវទោសករត្រូវសមាមាត្រជានិច្ចទៅនឹងកាលៈទេសៈនៃយុវទោសករ និង បទល្មើស ។

សេចក្តីអធិប្បាយ

វិធាន ៥ សំដៅដល់ទិសដៅពីរក្នុងបណ្តាទិសដៅសំខាន់ៗបំផុតនៃយុត្តិធម៌យុវជន ។ ទិសដៅទីមួយ គឺការលើកស្ទួយ សុខមាលភាពរបស់យុវជន ។ នេះជាចំណុចផ្តោតចំបងនៃប្រព័ន្ធច្បាប់ទាំងឡាយ ដែលនៅក្នុងប្រព័ន្ធនោះយុវទោសករ ត្រូវបានចាត់ការដោយតុលាការគ្រួសារ ឬអាជ្ញាធររដ្ឋបាល ប៉ុន្តែ ក៏ត្រូវផ្តោតលើសុខមាលភាពរបស់យុវជនដែរ នៅក្នុង ប្រព័ន្ធច្បាប់ទាំងឡាយណាដែលជ្រើសរើសគំរូតុលាការព្រហ្មទណ្ឌ ដូច្នេះហើយការនេះរួមចំណែកក្នុងការចៀសវាង ទណ្ឌកម្មដែលមានលក្ខណៈត្រឹមតែប្រដៅយុវជន (សូមមើលវិធាន ១៨) ។

ទិសដៅទីពីរគឺ គោលការណ៍នៃភាពសមាមាត្រ ៉ ។ គោលការណ៍មានឈ្មោះល្បីថា ជាឧបករណ៍សំរាប់ទប់ទណ្ឌកម្ម ដែលមានលក្ខណៈជាការប្រដៅ ដែលភាគច្រើនគេហៅថាការទទួលអ្វីដែលសមនឹងទទួលធៀបទៅនឹងទម្ងន់នៃបទល្មើស។ ការឆ្លើយតបចំពោះយុវទោសករត្រូវមានមូលដ្ឋាននៃការពិចារណាមិនត្រឹមតែលើទម្ងន់នៃបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែលើ កាលៈទេសៈផ្ទាល់ខ្លួនផងដែរ ។ កាលៈទេសៈផ្ទាល់ខ្លួនរបស់យុវទោសករម្នាក់ៗ (ឧទាហរណ៍ ឋានៈសង្គម ស្ថានភាព គ្រួសារ ការខូចខាតបណ្តាលមកពីបទល្មើស ឬកត្តាដទៃទៀតដែលមានផលប៉ះពាល់ដល់កាលៈទេសៈផ្ទាល់ខ្លួន) ត្រូវមាន ឥទ្ធិពលលើភាពសមាមាត្រនៃប្រតិកម្ម (ឧទាហរណ៍ ដោយគិតដល់ការខ្នះខ្នែងរបស់យុវទោសករដើម្បីជួសជុលការ ខូចខាតរបស់ជនរងគ្រោះ ឬ សុឆន្ទៈរបស់គេក្នុងការត្រឡប់មករកជីវិតត្រឹមត្រូវ និងមានប្រយោជន៍) ។

ក្នុងរបៀបដូចគ្នាដែរ ប្រតិកម្មដែលសំដៅធានាសុខមាលភាពរបស់ជនល្មើសវ័យក្មេងអាចហួសពីភាពចាំបាច់ ហើយហេតុនេះរំលោភបំពានលើសិទ្ធិជាមូលដ្ឋានមនុស្សក្មេង ដូចគេបានសង្កេតឃើញនៅក្នុងប្រព័ន្ធយុត្តិធម៌យុវជនខ្លះ ។ នៅទីនេះ ត្រូវការពារភាពសមាមាត្រនៃ

ប្រតិកម្មទៅនឹងកាលៈទេសៈនៃជនល្មើស និង បទល្មើសហើយត្រូវការពារជន រងគ្រោះផងដែរ ។

ជាសំខាន់វិធាន ៥ អំពាវនាវសុំកុំឱ្យមានប្រតិកម្មតិចជាង និងធំជាង ប្រតិកម្មសមរម្យនៅក្នុងករណីនានានៃ ទោសកម្ម និងឧក្រិដ្ឋកម្មរបស់យុវជន ។ បញ្ហាដែលបញ្ចូលនៅក្នុងវិធានអាចជួយជំរុញឱ្យកើតមានរឿងទាំងពីរ ៖ ប្រភេទនៃប្រតិកម្មថ្មី និងប្លែកល្មមនឹងទទួលយកបានជាការប្រយ័ត្នទុកជាមុនទប់ទល់នឹងការពង្រីកមិនត្រឹមត្រូវនូវវង្វង់ ត្រួតត្រាផ្លូវការរបស់សង្គមលើយុវជន ។

៦. វិសាលភាពនៃឆន្ទានុសិទ្ធិ

៦.១. ដោយពិចារណាឃើញថា សេចក្តីត្រូវការពិសេសខុសៗគ្នារបស់យុវជនព្រមទាំងវិធានការណ៍ ប្លែកៗគ្នា ដែលមានវិសាលភាពសមស្របសំរាប់អនុវត្តឆន្ទានុសិទ្ធិត្រូវតែបានអនុញ្ញាតឱ្យមាន នៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី ហើយនិងនៅលំដាប់ថ្នាក់ផ្សេងៗនៃការគ្រប់គ្រង វិស័យយុត្តិធម៌យុវជនរួមមានការស៊ើបអង្កេតការចោទប្រកាន់ ការវិនិច្ឆ័យ និងការអនុវត្តន៍ សេចក្តីសំរេច ។

៦.២. ក៏ប៉ុន្តែ ត្រូវប្រឹងប្រែងធានាអោយមានការទទួលខុសត្រូវគ្រប់គ្រាន់នៅគ្រប់ដំណាក់កាល និង លំដាប់ថ្នាក់ទាំងអស់ក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិនោះ ។

៦.៣. អ្នកដែលអនុវត្តឆន្ទានុសិទ្ធិត្រូវមានគុណសម្បត្តិ ឬទទួលការហ្វឹកហ្វឺនជាពិសេសដើម្បីអនុវត្ត ឆន្ទានុសិទ្ធិនោះដោយវិចារណញ្ញាណ និង ស្របតាមមុខងារ និងអំណាចដែលគេប្រគល់អោយខ្លួន។

សេចក្តីអធិប្បាយ

វិធាន ៦.១, ៦.២ និង ៦.៣ រួមបញ្ចូលគ្នានូវលក្ខណៈសំខាន់ៗជាច្រើននៃការគ្រប់គ្រងយុត្តិធម៌យុវជន ប្រកបដោយប្រសិទ្ធិភាពត្រឹមត្រូវ និងក្នុងភាពជាមនុស្ស ៖ ការចាំបាច់ត្រូវអនុញ្ញាតឱ្យអនុវត្តអំណាចឆន្ទានុសិទ្ធិ នៅគ្រប់លំដាប់ថ្នាក់ចាត់ការសំខាន់ៗទាំងអស់ ដើម្បីឱ្យអ្នកដែលធ្វើសេចក្តីសំរេចអាចចាត់វិធានការណាដែលចាត់ ទុកថាសមស្របបំផុតនៅក្នុងករណីនីមួយៗ ហើយការចាំបាច់ត្រូវផ្តល់ការត្រួតពិនិត្យ និងថ្លឹងថ្លែងគ្នាទៅវិញទៅមក ដើម្បីទប់ការរំលោភបំពានអំណាចឆន្ទានុសិទ្ធិ និងដើម្បីរក្សាការពារសិទ្ធិរបស់ជនល្មើសវ័យក្មេង ។ ការទទួល ខុសត្រូវ និងលក្ខណៈសម្បត្តិខាងវិជ្ជាជីវៈ គឺជាឧបករណ៍ប្រសើរបំផុតអាចទប់ទល់នឹងឆន្ទានុសិទ្ធិទូលំទូលាយ ។ ដូច្នេះលក្ខណៈសម្បត្តិខាងវិជ្ជាជីវៈ និងការហ្វឹកហ្វឺនឱ្យទៅជាអ្នក

ជំនាញគឺជាចំណុច សំខាន់ដែលចាត់ទុកជា មធ្យោបាយមានតំលៃ ដើម្បីធានាការអនុវត្តន៍ឆន្ទានុសិទ្ធិប្រកបដោយវិចារណញ្ញាណ ក្នុងបញ្ហាយុវទោសករ ។ (សូមមើលវិធាន ១.៦ និង ២.២) ។ ការកំណត់គោលការណ៍ណែនាំជាក់លាក់ ស្តីពីការអនុវត្តន៍ឆន្ទានុសិទ្ធិ និងការផ្តល់ឱ្យមានប្រព័ន្ធពិនិត្យឡើងវិញ ការធ្វើឧទ្ធរណ៍ និងប្រព័ន្ធស្រដៀងគ្នានេះ ដើម្បីអាចពិនិត្យពិច័យ សេចក្តីសំរេច និងការទទួលខុសត្រូវគឺមានដៅបញ្ជាក់នៅក្នុងបរិបទនេះ ។ យន្តការបែបនោះមិនបានបញ្ជាក់នៅ ទីនេះទេ ព្រោះយន្តការទាំងនេះមិនងាយនឹងបញ្ចូលទៅក្នុងវិធានជាបទដ្ឋាន អប្បបរមាអន្តរជាតិបានទេ ព្រោះវាមិនអាចគ្របដណ្តប់លើភាពខុសគ្នារវាងប្រព័ន្ធយុត្តិធម៌មួយ ទៅប្រព័ន្ធ មួយទៀត ។

## ៧. សិទ្ធិរបស់យុវជន

៧.១. កិច្ចការពារតាមនីតិវិធីជាមូលដ្ឋាន ដូចជាសច្ចធារណ៍នៃនិរទោស សិទ្ធិត្រូវបានការជូនដំណឹងពី ការចោទប្រកាន់ សិទ្ធិមិននិយាយស្តី សិទ្ធិមានអ្នកផ្តល់យោបល់ សិទ្ធិមានវត្តមានរបស់ឪពុក/ ម្តាយ ឬអាណាព្យាបាល សិទ្ធិដើម្បីតទល់និងសួរតតាំងសាក្សី និងសិទ្ធិធ្វើឧទ្ធរណ៍ទៅអាជ្ញាធរ ថ្នាក់លើជាដើម ត្រូវតែបានធានានៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី ។

### សេចក្តីអធិប្បាយ

វិធាន ៧.១ ដៅបញ្ជាក់ចំណុចសំខាន់ខ្លះៗ ដែលតំណាងឱ្យធាតុផ្សំសំខាន់សំរាប់ការជំនុំជំរះត្រឹមត្រូវ និង យុត្តិធម៌ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅក្នុងឧបករណ៍សិទ្ធិមនុស្ស ដែលមានមកហើយ (សូម មើលវិធាន ១៤) ។ ឧទាហរណ៍ សច្ចធារណ៍នៃនិរទោសមាននៅក្នុងមាត្រា ១១ នៃសេចក្តីថ្លែងការណ៍សកល អំពីសិទ្ធិមនុស្ស និងនៅក្នុង មាត្រា ១៤ កថាខ័ណ្ឌ ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

វិធាន ១៤ នៃវិធានជាបទដ្ឋានអប្បបរមានេះ បញ្ជាក់ពីបញ្ហាដែលមានសារៈសំខាន់ជាពិសេសដល់នីតិវិធី ក្នុង ករណីយុវជន ចំណែកឯវិធាន ៧.១ ធានាអះអាងកិច្ចការពារតាមនីតិវិធីជាមូលដ្ឋាននៅក្នុងបែបជួយជា ទូទៅ ។

## ៨. ការការពារភាពជាឯកជន

៨.១. សិទ្ធិរបស់យុវជនក្នុងភាពជាឯកជនត្រូវបានគោរពនៅគ្រប់ដំណាក់កាលទាំងអស់ ដើម្បីចៀសវាងការ ខូចខាតដល់យុវជន ដោយសារតែការផ្សព្វផ្សាយមិនសមរម្យ ឬដោយសារការលាបពណ៌។

៨.២. ជាគោលការណ៍មិនត្រូវបោះពុម្ពផ្សាយពត៌មានដែលនាំអោយគេស្គាល់យុវទោសករឡើយ ។

សេចក្តីអធិប្បាយ

វិធាន ៨ សង្កត់ខ្លាំងលើសារៈសំខាន់នៃការការពារសិទ្ធិភាពជាឯកជនរបស់យុវជន ។ មនុស្សក្មេងៗងាយនិងឹ អាប់អោនឈ្មោះ ។ ការស្រាវជ្រាវតាមបែបឧក្រិដ្ឋវិទ្យាអំពីការលាបពណ៌បានបង្ហាញភស្តុតាងអោយ ឃើញផលមិនល្អ ធ្វើអោយខូចប្រយោជន៍ក្មេងៗ ដែលកើតចេញពីការសំគាល់ក្មេងៗនោះជា ទោ៉សករ ៉ ឬ ឧ៉ក្រិដ្ឋជន ៉ ។

វិធាន ៨ សង្កត់ធ្ងន់លើសារៈសំខាន់នៃការការពារយុវជនអោយរួចផុតពីផលមិនល្អ ដែលអាចកើតចេញពីការ បោះពុម្ពផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយពត៌មាន អំពីពត៌មានទាក់ទិននឹងរឿងក្តី (ឧទាហរណ៍ ឈ្មោះរបស់យុវទោសករ ដែលត្រូវបានចោទប្រកាន់ក្តី ឬត្រូវបានកាត់ទោសរួចទៅហើយក្តី ) ។ ផលប្រយោជន៍ របស់បុគ្គលត្រូវតែបានការពារ និងគាំទ្រយ៉ាងហោចណាស់ក្នុងលក្ខណៈជាគោលការណ៍ដែរ (ខ្លឹមសារទូទៅនៃ វិធាន ៨ មានបញ្ជាក់តទៅទៀតក្នុងវិធាន ២.១) ។

៩. ឧបង្កា

៩.១. អ្វីទាំងអស់នៅក្នុងវិធានទាំងនេះ មិនត្រូវបកស្រាយដើម្បីច្រានចោលការអនុវត្តន៍បញ្ញត្តិជាបទដ្ឋាន អប្បបរមា ស្តីពីការគ្រប់គ្រងអ្នកទោសដែលអនុម័តដោយសហប្រជាជាតិ ហើយនិងឧបករណ៍សិទ្ធិ មនុស្សដទៃទៀត និង បទដ្ឋាននានាដែលទទួលស្គាល់ដោយសហគមន៍អន្តរជាតិ និង ដែលទាក់ទងទៅ នឹងការថែទាំនិងការការពារក្មេង ។

សេចក្តីអធិប្បាយ

វិធាន ៩ ចង់អោយចៀសវាងការយល់ខុសណាមួយក្នុងការបកស្រាយ និងអនុវត្តវិធានក្នុងឯកសារនេះ ស្របតាម គោលការណ៍ដែលមាននៅក្នុងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ

ដែលមានមកហើយ ឬ កំពុងតែលេចឡើង និងបទដ្ឋាន នានា ដូចជាសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងសេចក្តីថ្លែងការណ៍អំពីសិទ្ធិកុមារ និងសេចក្តីព្រាង អនុសញ្ញាអំពីសិទ្ធិកុមារ ។ គេត្រូវយល់ថាការអនុវត្តន៍វិធាននៅក្នុងឯកសារនេះ គឺគ្មានប៉ះពាល់ធ្វើអោយខូចប្រយោជន៍ នៃឧបករណ៍អន្តរជាតិណាមួយ ដែលមានបញ្ញត្តិសំរាប់អនុវត្តទូលំទូលាយជាងនេះឡើយ ។(សូមមើលវិធាន ២៧) ។

ផ្នែកទី ២

ការស៊ើបអង្កេត និងការចោទប្រកាន់

១០. ការពើបប្រទះដើមដំបូង

១០.១. នៅពេលចាប់ខ្លួនយុវជនណាមួយភ្លាម ត្រូវជូនដំណឹងជាបន្ទាន់ដល់ឪពុកម្តាយ ឬ អាណាព្យាលយុវជននោះ អោយបានដឹងពីការចាប់ខ្លួន ហើយក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់ត្រូវជូនដំណឹងដល់ឪពុកម្តាយ ឬអាណាព្យាបាលក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើបាន ចាប់ពីពេលចាប់ខ្លួននោះទៅ ។

១០.២. ចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ច ឬអង្គការផ្សេងទៀត ត្រូវពិចារណាលើបញ្ហាដោះលែងដោយគ្មាន បង្អង់ ។

១០.៣. ការពើបប្រទះរវាងទីភ្នាក់ងារអនុវត្តច្បាប់ និងយុវទោសករ ត្រូវធ្វើក្នុងបែបណាមួយដែលគោរពស្ថានភាព គតិយុត្តិរបស់យុវជនលើកស្ទួយសុខមាលភាពរបស់យុវជន និងចៀសវាងការប៉ះពាល់ដល់រូបគេ ដោយ ពិចារណាឱ្យជិតដល់ទៅលើកាលៈទេសៈ នៃករណីរបស់យុវជននោះ ។

សេចក្តីអធិប្បាយ

វិធាន ១០.១ ជាគោលការណ៍ស្ថិតនៅក្នុងវិធាន ៩២ នៃបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស ។ បញ្ហាដោះលែង (វិធាន ១០.២) ត្រូវពិចារណាដោយគ្មានបង្អែបង្អង់ដោយចៅក្រមម្នាក់ ឬមន្ត្រីមានសមត្ថកិច្ចដទៃទៀត។ មន្ត្រីមានសមត្ថកិច្ចនេះសំដៅដល់ជនណាម្នាក់ ឬស្ថាប័នណាមួយក្នុងន័យទូលំទូលាយ រួមមានគណៈកម្មការសហគមន៍ ឬ អាជ្ញាធរនគរបាលដែលមានអំណាចដោះលែងជនដែលត្រូវបានចាប់ខ្លួន ។ (សូមមើលកតិកាសញ្ញា

អន្តរជាតិ ស្តីពីសិទ្ធិ ពលរដ្ឋ និងនយោបាយមាត្រា ៩ កថាខ័ណ្ឌ ៣) ។ វិធាន ១០.៣ ទាក់ទង នឹងទិដ្ឋភាពជាមូលដ្ឋានខ្លះនៃនីតិវិធី និង អាកប្បកិរិយារបស់នគរបាល និងមន្ត្រីអនុវត្តច្បាប់ ដទៃទៀតក្នុងករណីមានឧក្រិដ្ឋកម្មរបស់យុវជន ។ ពាក្យថា ចៀសវាង កុំអោយប៉ះពាល់ ឬធ្វើអោយខូចខាត ៉ គឺជាពាក្យអាចបត់បែនបានមិនមែនរឹងកំព្រឹសទេ ហើយពាក្យនេះគ្របដណ្តប់ ទ្រង់ទ្រាយជាច្រើនដែលអាចមានមកពីការបញ្ចោញសកម្មភាពរកគ្នាទៅវិញទៅមក (ឧទាហរណ៍ ការប្រើភាសាគំរោះ- គំរើយ ការធ្វើអំពើហឹង្សាលើរូបកាយ ឬការជួបប្រទះបរិយាកាសជុំវិញ) ។ កាលណាមានការពាក់ព័ន្ធនៅក្នុងដំណើរការ យុត្តិធម៌ យុវជនវាអាចនឹងមានការ ប៉ះពាល់ ឬ ខូចខាត ៉ ដល់យុវជន ។ ដូច្នេះ ពាក្យ ចៀសវាងកុំឱ្យប៉ះពាល់ ឬការខូចខាតត្រូវបកស្រាយឱ្យបានទូលំទូលាយ គឺធ្វើយ៉ាងណាអោយការប៉ះពាល់ ឬការខូចខាតនោះអោយនៅតិចបំផុត ដែល អាចធ្វើទៅបាននៅគ្រាដំបូង ។ ការប៉ះពាល់ក្រោយមកទៀត ឬការប៉ះពាល់ដែលមិនត្រឹមត្រូវដទៃទៀតក៏ត្រូវបន្ថយឱ្យ នៅតិចបំផុតដែរ ។ ការនេះសំខាន់ណាស់ ជាពិសេសនៅពេលដែលយុវជនបានធ្វើពើបប្រទះទីភ្នាក់ងារអនុវត្តច្បាប់ដំបូង ដែលអាចជះឥទ្ធិពលដ៏ជ្រៅដល់ឥរិយាបថយុវជនចំពោះរដ្ឋ និងសង្គម ។ ជាងនេះទៅទៀត ជោគជ័យនៃការធ្វើអន្តរាគមន៍ នៅលើកក្រោយតទៅទៀតអាស្រ័យយ៉ាងខ្លាំងលើការពើបប្រទះដំបូងនេះ ។ សេចក្តីមេត្តា និងភាពម៉ឹងម៉ាត់គឺជាការ សំខាន់ក្នុងស្ថានការទាំងនេះ ។

១១. ការបង្វែចេញពីដំណើរការតុលាការ

១១.១. ក្នុងករណីដែលអាចធ្វើទៅបានត្រូវពិចារណាដោះស្រាយរឿងយុវទោសករ ដោយមិនបាច់យកទៅជំនុំជំរះ ជាផ្លូវការដោយអាជ្ញាធរមានសមត្ថកិច្ច ដូចចែងក្នុងវិធាន ១៤.១ ខាងក្រោម ។

១១.២. ត្រូវទុកអំណាចអោយនគរបាលអយ្យការ ឬទីភ្នាក់ងារដទៃទៀត ដែលដោះស្រាយរឿងរបស់យុវជន សំរេចរឿងនោះតាមឆន្ទានុសិទ្ធិរបស់គេ ដោយមិនបាច់រកផ្លូវដោះស្រាយតាមសវនការជាផ្លូវការ ដោយ អនុលោមតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗសំរាប់គោលបំណងនោះ និងស្របតាមគោលការណ៍ដែលមានក្នុងវិធាននានានៅទីនេះដែរ ។

១១.៣. ការបង្វែចេញពីដំណើរការតុលាការអោយទៅសហគមន៍ ឬ សេវាកម្មដទៃទៀតដែលសមស្រប ត្រូវតែ មានការយល់ព្រមពីយុវជន ឬ ឪពុកម្តាយ ឬ អាណា

ព្យាបាលរបស់គេ ហើយលុះត្រាតែការសំរេចបង្វែ ចេញពីដំណើរការតុលាការ នោះបើកអោយអាជ្ញាធរមានសមត្ថកិច្ចពិនិត្យសិននៅពេលដាក់ពាក្យសុំបង្វែ ចេញ ។

11.4> ដើម្បីជួយសំរួលការសំរេចបញ្ចប់រឿងរបស់យុវជនដោយឆន្ទានុសិទ្ធិ ត្រូវប្រឹងប្រែងបង្កើតកម្មវិធីរបស់ សហគមន៍ដូចជាការត្រួតពិនិត្យ និងការណែនាំជាបណ្តោះអាសន្ន ការជួសជុលឡើងវិញ និងការទូទាត់ ការខូចខាតដល់ជនរងគ្រោះ ។

សេចក្តីអធិប្បាយ

ការបង្វែចេញពីដំណើរការតុលាការ ដែលពាក់ព័ន្ធនឹងការដកចេញពីដំណើរការជំនុំជំរះបទព្រហ្មទណ្ឌ និងជាញឹកញាប់ លើករឿងទៅអោយសេវាកម្មគាំទ្ររបស់សហគមន៍ដោះស្រាយវិញ នោះគឺជាការដែលគេអនុវត្តជាទូទៅតាមបែប ផ្លូវការផង និងមិនផ្លូវការផងនៅក្នុងប្រព័ន្ធច្បាប់ជាច្រើន ។ ការអនុវត្តន៍នេះសំរាប់បន្ទុកបង្អាក់ផលជាអវិជ្ជមានពីនីតិវិធី ជំនុំជំរះបន្តបន្ទាប់នៅក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌យុវជន (ឧទាហរណ៍ ការឱ្យដឹងសុសសាយពីការផ្តន្ទាទោស) ។ ក្នុងករណីជាច្រើនការមិនធ្វើអន្តរាគមន៍គឺជាដំណោះស្រាយដ៏ល្អបំផុត ។ ដូច្នេះ ការបង្វែចេញពីដំណើរការតុលាការនៅពី ដើមទីមិនបាច់លើករឿងទៅអោយសេវាកម្ម (សង្គម) ដោះស្រាយជំនួសតុលាការអាចជាចំលើយជាទីគាប់ចិត្ត ។ ការ នេះល្អសំរាប់រឿងដែលមានបទល្មើសមិនធ្ងន់ធ្ងរ ហើយគ្រួសារ ឬស្ថាប័នឃុំគ្រងមិនផ្លូវការដទៃទៀតរបស់សង្គមបាន បញ្ចោញប្រតិកម្មរួចហើយ ឬ ទំនងជានឹងបញ្ចោញប្រតិកម្មក្នុងរបៀបមួយដ៏សមស្រប និងដោយស្ថាបនា ។

ដូចបានថ្លែងក្នុងវិធាន ១១.២ រួចមកហើយថា ការបង្វែចេញពីដំណើរការតុលាការអាចប្រើនៅចំណុចណាក៏បាន នៃការសំរេចចិត្តរបស់នគរបាល អយ្យការ ឬ ទីភ្នាក់ងារដទៃទៀត ដូចតុលាការសាលាជំនុំជំរះក្តី ឬក្រុមប្រឹក្សា ។ ការ បង្វែចេញពីដំណើរការតុលាការនេះ អាចអនុវត្តបានដោយអាជ្ញាធរម្នាក់ ឬច្រើននាក់ ឬទាំងអស់គ្នាស្របទៅតាមវិធាន និងគោលនយោបាយរបស់ប្រព័ន្ធប្រទេសនីមួយៗ និងស្របតាមវិធានបច្ចុប្បន្ននេះ ។ ការបង្វែចេញពីដំណើរការតុលាការ មិនចាំបាច់សំរាប់តែរឿងតូចតាចនោះទេ ដូច្នេះធ្វើអោយការបង្វែរឿងជាឧបករណ៍មួយដ៏សំខាន់ ។

វិធាន ១១.៣ ដៅសំខាន់លើការតម្រូវឱ្យមានការយល់ព្រមពីយុវទោសករ (ឬឪពុកម្តាយ ឬអាណាព្យាបាល) ចំពោះវិធានការបង្វែចេញពីដំណើរការតុលាការដែលបានស្នើឡើង ។

(ការបង្វែទៅអោយធ្វើកិច្ចការបំរើសហគមន៍ ដោយគ្មានការយល់ព្រមពីយុវទោសករ គឺផ្ទុយនឹងអនុសញ្ញាដើម្បីបំបាត់ការងារដោយបង្ខំ) ។ ប៉ុន្តែការយល់ព្រមនេះ មិនត្រូវបណ្តោយដោយគ្មានការតវ៉ានោះទេ ព្រោះថា ជួនកាលយុវជនយល់ព្រមទាំងប្រថុយប្រថាន ។ វិធាននេះគូសបញ្ជាក់ថា គេត្រូវយកចិត្តទុកដាក់កាត់បន្ថយសក្តានុពលនៃការបង្ខិតបង្ខំអោយនៅតិចតួចបំផុតនៅគ្រប់កំរិតទាំងអស់នៃ ដំណើរការបង្វែចេញពីដំណើរការតុលាការ ។ យុវជនមិនត្រូវជិតដាមដោយអារម្មណ៍ត្រូវគេកៀបសង្កត់ឡើយ (ឧទាហរណ៍ ដូចជាដើម្បីចៀសវាងការឡើងទៅតុលាការ) ឬមិនត្រូវទទួលការកៀបសង្កត់ឱ្យយល់ព្រមទទួលតាមកម្មវិធីអប់រំក្រៅ តុលាការ ។ ដូច្នេះសូមរំលឹកថា បញ្ញត្តិនៃវិធានការនេះត្រូវអនុវត្តដោយមានការវាយតម្លៃជាសត្យានុម័តលើភាព សមស្របនៃការសំរេចរបស់ អាជ្ញាធរមានសមត្ថកិច្ច ៉ ពាក់ព័ន្ធនឹងយុវទោសករ ។ ( អាជ្ញាធរ មានសមត្ថកិច្ច ៉ អាចផ្សេងពីអ្វីដែលបានពោលក្នុងវិធាន ១៤) ។

វិធាន ១១.៤ ស្នើឱ្យរកមធ្យោបាយជំនួសដែលអាចធ្វើទៅបានសំរាប់ចាត់ការយុត្តិធម៌យុវជន ក្នុងរបៀបជាការ បង្វែរឿងឱ្យទៅបំរើសហគមន៍ ។ កម្មវិធីដែលពាក់ព័ន្ធនិងដំណោះស្រាយដោយស្តារលទ្ធភាពជនរងគ្រោះ និងអ្នកដែល ព្យាយាមចៀសវាងទំនាស់តទៅអនាគតជាមួយនឹងច្បាប់តាមរយៈការត្រួតពិនិត្យជាបណ្តោះអាសន្ន និងការណែនាំគួរតែ ពិចារណាធ្វើ ។ បើរឿងណាសមនឹងបង្វែជាការគួរៗតែបង្វែសូម្បីតែបទល្មើសដែលបានប្រព្រឹត្តនោះធ្ងន់យ៉ាងណាក៏ដោយ (ឧទាហរណ៍ បទល្មើសទើបតែប្រព្រឹត្តលើកទីមួយការប្រព្រឹត្តក្រោមការកៀបសង្កត់ពីគូកន ។ល។)

១២. ឯកទេសក្នុងអង្គភាពនគរបាល

១២.១. ដើម្បីបំពេញមុខងាររបស់គេឱ្យបានប្រសើរបំផុត មន្ត្រីនគរបាលដែលទាក់ទិនជារឿយៗ ឬ ទាក់ទិន តែជាមួយរឿងយុវជន ឬ មន្ត្រីនគរបាលដែលជាប់ពាក់ព័ន្ធជាពិសេស ក្នុងរឿងទប់ស្កាត់ឧក្រិដ្ឋកម្មរបស់ យុវជន ត្រូវទទួលការណែនាំ និងហ្វឹកហ្វឺនជាពិសេស ។ នៅក្នុងក្រុងធំៗ អង្គភាពពិសេសនៃនគរបាល ត្រូវតែបានបង្កើតឡើងសំរាប់គោលបំណងនេះ ។

សេចក្តីអធិប្បាយ

វិធាន ១២ សុំឱ្យយកចិត្តទុកដាក់ដល់ភាពចាំបាច់នៃការបង្វឹកបង្វឹនឯកទេសដល់មន្ត្រីអនុវត្តច្បាប់ថ្មីៗទាំងអស់ដែល ពាក់ព័ន្ធនឹងការគ្រប់គ្រងយុត្តិធម៌យុវជន ។ ដោយសារនគរបាលជាចំណុចពើបប្រទះដំបូងជាមួយប្រព័ន្ធយុត្តិធម៌យុវជន ជាការសំខាន់បំផុតដែលនគរបាលធ្វើសកម្មភាពក្នុងរបៀបមួយដ៏សមរម្យ និង ដោយមានការយល់ដឹង ។ ក្នុងខណៈដែល ទំនាក់ទំនងរវាងជីវភាពទីក្រុង និង ឧក្រិដ្ឋកម្មពិតជាមានលក្ខណៈស្មុគ្រស្មាញមែននោះ ការកើនឡើងនៃឧក្រិដ្ឋកម្មរបស់ យុវជនមានចំណងទាក់ទងនឹងការរីកដុះដាលនៃទីក្រុងធំៗ ជាពិសេសការដុះដាលលឿនហើយដែលគ្មានផែនការ ។ ដូច្នេះ អង្គភាពននគរបាលឯកទេស ពិតជាត្រូវបង្កើតឱ្យមានដោយខានមិនបានមិនត្រឹមតែដើម្បីអនុវត្តគោលការណ៍ជាក់លាក់ ដែលមាននៅក្នុងឧតុបករណ៍នេះទេ (ដូចជា វិធាន ១.៦ ជាដើម) ប៉ុន្តែជាទូទៅដើម្បីបង្កើតការត្រួតត្រាឧក្រិដ្ឋកម្ម យុវជន និងការចាត់ការ និងគ្រប់គ្រងយុវទោសករ ។

១៣. ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះ

១៣.១. ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះ ត្រូវប្រើជាវិធានការចុងក្រោយបង្អស់ប៉ុណ្ណោះ ហើយសំរាប់តែ រយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ។

១៣.២. ក្នុងករណីណាដែលអាចធ្វើទៅបាន ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះ ត្រូវជំនួសដោយវិធានផ្សេង ដូចជា ការឃ្លាំមើលដោយជិតដល់ការថែទាំហ្មត់ចត់ ឬការដាក់ឱ្យនៅជាមួយគ្រួសារមួយ ឬនៅក្នុងទីកន្លែង ឬ ផ្ទះសំរាប់អប់រំ ។

១៣.៣. យុវជនដែលត្រូវឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះ ត្រូវទទួលបានសិទ្ធិ និងការធានារ៉ាប់រងទាំងអស់នៃ បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោសដែលអនុម័តដោយអង្គការសហប្រជាជាតិ ។

១៣.៤. យុវជនដែលត្រូវឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះ ត្រូវទុកឱ្យនៅដាច់ពីមនុស្សធំពេញវ័យ ហើយត្រូវឃុំទុក ក្នុងគ្រឹះស្ថានដោយឡែក ឬនៅក្នុងផ្នែកណាមួយដាច់ដោយឡែកពីគ្រឹះស្ថានដែលឃុំមនុស្សធំពេញវ័យ ដែរនោះ ។

១៣.៥. ក្នុងខណៈដែលស្ថិតក្នុងការឃុំឃាំង យុវជនត្រូវទទួលការថែទាំការការពារ និងការទំនុកបំរុងផ្ទាល់ខ្លួន ទាំងអស់ដែលចាំបាច់ ដូចជាការទំនុកបំរុងផ្នែកសង្គម

អប់រំ វិជ្ជាជីវៈ ចិត្តសាស្ត្រពេទ្យ និងផ្លូវកាយ ដែល គេអាចត្រូវការដោយយោលទៅលើអាយុ ភេទ និង បុគ្គលិកលក្ខណៈ ។

*សេចក្តីអធិប្បាយ*

*គេមិនត្រូវមិនគិតដល់ការគ្រោះថ្នាក់នៃ ការប្រឡាក់ប្រឡូកខាងឧក្រិដ្ឋកម្ម ៉ ដល់យុវជនក្នុងពេលឃុំឃាំងដើម្បី រង់ចាំការជំនុំជំរះនោះទេ ។ ដូច្នេះ ជាការសំខាន់ត្រូវយកចិត្តទុកដាក់ខ្លាំងលើសេចក្តីត្រូវការឱ្យមានវិធានការណ៍ជំនួស ។ ដើម្បីធ្វើដូច្នេះបានវិធាន ១៣.១ លើកទឹកចិត្តដើម្បីផ្តួចផ្តើមវិធានការថ្មី និង ការកែលំអដើម្បីចៀសវាងការឃុំឃាំងក្នុង ផលប្រយោជន៍នៃសុខមាលភាពរបស់យុវជន ។*

*យុវជនដែលត្រូវឃុំឃាំងដើម្បីរង់ចាំការជំនុំជំរះត្រូវទទួលបានសិទ្ធិ និងការធានារ៉ាប់រងទាំងអស់នៃបញ្ញត្តិជាបទដ្ឋាន អប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស ព្រមទាំងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ជាពិសេស មាត្រា ៩ និង មាត្រា ១០ កថាខ័ណ្ឌ២ (ខ) និង ៣ ។*

*វិធាន ១.៤ មិនបានរារាំងរដ្ឋនានាមិនឱ្យចាត់វិធានការដទៃទៀតទប់ទល់នឹងឥទ្ធិពលអវិជ្ជមាននៃជនល្មើសជា មនុស្សពេញវ័យដែលជាវិធានការយ៉ាងហោចណាស់មានប្រសិទ្ធិភាពស្មើនឹងវិធានការដែលមានបញ្ជាក់ក្នុងវិធាននេះទេ ។*

*ការជួយឧបត្ថម្ភទំនុកបំរុងដែលមានទម្រង់ផ្សេងៗដែលអាចចាត់ទុកថាចាំបាច់ ត្រូវបានរៀបរាប់ដើម្បីទាញការ យកចិត្តទុកដាក់ដល់សេចក្តីត្រូវការពិសេសមួយចំនួនធំរបស់ក្មេងៗដែលត្រូវឃុំឃាំង (ឧទាហរណ៍ ក្មេងស្រី ឬក្មេងប្រុស អ្នកញៀន អ្នកផឹកស្រា យុវជនដែលមានវិបត្តិស្មារតី ក្មេងដែលទទួលការឈឺចាប់ ឧទាហរណ៍ ពីការចាប់ខ្លួនជាដើម ។ល។) ។*

*លក្ខណៈខុសៗគ្នាខាងផ្លូវកាយនិងចិត្តសាស្ត្រនៃក្មេងដែលជាប់ឃុំឃាំង អាចតម្រូវឱ្យមានវិធានការបំបែកប្រភេទ គឺថា ក្មេងខ្លះត្រូវទុកឱ្យនៅដោយឡែកនៅពេលរង់ចាំការជំនុំជំរះ ដូច្នេះគេអាចចៀសវាងកុំទុកឱ្យក្មេងក្លាយជាអ្នករងគ្រោះ ពីការឃុំឃាំងនោះ ហើយក្នុងលក្ខណៈនេះអាចឱ្យមានការជួយទំនុកបំរុងដ៏សមស្របដល់ក្មេងៗទាំងនោះផង ។*

*សមាជលើកទី ៦ នៃសហប្រជាជាតិស្តីពីការបង្ការឧក្រិដ្ឋកម្ម និងការគ្រប់គ្រងជនល្មើសនៅក្នុងសេចក្តីសំរេចលេខ ៤ ស្តីពីបទដ្ឋានយុត្តិធម៌យុវជនបានដៅបញ្ជាក់ថា វិធានក្នុងអត្ថបទ*

នេះជាអាទិ៍ ត្រូវឆ្លុះបញ្ចាំងឱ្យឃើញពីគោលការណ៍ មូលដ្ឋានថា ការឃុំឃាំងមុនពេលជំនុំជំរះ ត្រូវប្រើសំរាប់តែក្នុងមធ្យោបាយចុងក្រោយបង្អស់ប៉ុណ្ណោះ គឺគ្មានអនីតិជនណា ម្នាក់ត្រូវឃុំ ឃាំងទុកក្នុងទីកន្លែងដែលងាយនឹងទទួលឥទ្ធិពលអវិជ្ជមានពីមនុស្សពេញវ័យដែលជាប់ឃុំ ឃាំងដូចគ្នាទេ និង ត្រូវយកចិត្តទុកដាក់លើសេចក្តីត្រូវការសំរាប់ដំណាក់កាលវិកដុះដាល របស់គេ ។

ផ្នែកទី ៣

ការវិនិច្ឆ័យ និង ការសំរេចសេចក្តី

១៤. អាជ្ញាធរមានសមត្ថកិច្ចវិនិច្ឆ័យ

១៤.១. ក្នុងករណីដែលរឿងរបស់យុវទោសករម្នាក់មិនបានបង្វែ (តាមវិធាន ១១) ទេ នោះ យុវទោសករនោះ ត្រូវចាត់ការដោយអាជ្ញាធរមានសមត្ថកិច្ច (តុលាការ សាលាជំរះក្តីក្រុមប្រឹក្សា ។ល។) យោងតាម គោលការណ៍នៃការជំនុំជំរះត្រឹមត្រូវ និងយុត្តិធម៌ ។

១៤.២. នីតិវិធីជំនុំជំរះត្រូវសំដៅបំរើឧត្តមប្រយោជន៍របស់យុវជន ហើយត្រូវប្រព្រឹត្តទៅ ក្នុងបរិយាកាស យោគយល់គ្នា ដែលបើកឱ្យយុវជនចូលរួមក្នុងនីតិវិធីនោះ ហើយ ឱ្យគេបានបញ្ចេញមតិរបស់គេដោយ សេរី ។

សេចក្តីអធិប្បាយ

មានការពិបាកក្នុងការកំណត់និយមន័យនៃពាក្យអង្គការ ឬ ជនមានសមត្ថកិច្ច ដែលហៅ ជាសាកលថា ជាអាជ្ញាធរ វិនិច្ឆ័យសេចក្តី ។ អាជ្ញាធរមានសមត្ថកិច្ច ៉ ត្រូវរាប់បញ្ចូលជនណា ដែលធ្វើជាអធិបតីលើតុលាការ ឬ សាលាជំនុំជំរះក្តី (មានសមាសភាពជាក្រុមម្នាក់ ឬច្រើន នាក់) រួមមានមន្ត្រីតុលាការដែលមានវិជ្ជាជីវៈ ឬមន្ត្រីធម្មតា ព្រមទាំង គណៈកម្មការរដ្ឋបាល ផងដែរ (ឧទាហរណ៍ ក្នុងប្រព័ន្ធរបស់រដ្ឋស្កុតឡិន និង ស្កង់ឌីណាវ) ឬទីភ្នាក់ងារមិនផ្លូវការ របស់ សហគមន៍ និងទីភ្នាក់ងារដោះស្រាយជម្លោះដទៃទៀតដែលមានលក្ខណៈជាអ្នកវិនិច្ឆ័យ សេចក្តី ។

នីតិវិធីសំរាប់ចាត់ការយុវទោស ទោះក្នុងករណីណាក៏ដោយ ត្រូវស្របតាមបទដ្ឋានអប្បបរ មា ដែលអនុវត្តបានជា សាកលចំពោះចុងចោទព្រហ្មទណ្ឌនៅក្រោមនីតិវិធីដែលហៅថា នីតិ វិធីត្រឹមត្រូវតាមច្បាប់ ៉។ ស្របតាមនីតិវិធី ត្រឹមត្រូវ ការជំនុំជំរះត្រឹមត្រូវ និងយុត្តិធម៌ ៉ រួម មានកិច្ចការពារជាមូលដ្ឋាន ដូចជាសច្ចធារណ៍នៃនិរទោសការបង្ហាញ និង ការសាកសួរសាក្សី

មធ្យោបាយការពារតាមផ្លូវច្បាប់សិទ្ធិនៅស្ងៀមមិននិយាយស្តី សិទ្ធិមានសំណូមពរចុងក្រោយ នៅ ក្នុងសវនាការ សិទ្ធិប្តឹងឧទ្ធរណ៍ ។ល។ (សូមមើលវិធាន ៧.១) ។

១៥. ទីប្រឹក្សាច្បាប់ ឪពុកម្តាយ និងអាណាព្យាបាល

១៥.១. នៅក្នុងអំឡុងពេលនីតិវិធីយុវជន ត្រូវមានសិទ្ធិឱ្យទីប្រឹក្សាច្បាប់ធ្វើជាតំណាងឱ្យខ្លួន ឬ មានសិទ្ធិស្នើសុំ ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃក្នុងករណីដែលមានជំនួយផ្នែកច្បាប់នៅក្នុងប្រទេសសាម៉ី ។

១៥.២. ឪពុកម្តាយ ឬអាណាព្យាបាលត្រូវមានសិទ្ធិចូលរួមក្នុងនីតិវិធី ហើយអាជ្ញាធរមានសមត្ថកិច្ចអាចតំរូវឱ្យ ឪពុកម្តាយ ឬអាណាព្យាបាលចូលរួមក្នុងនីតិវិធីដើម្បីប្រយោជន៍របស់យុវជន ។ ក៏ប៉ុន្តែ អាជ្ញាធរមាន សមត្ថកិច្ចអាចបដិសេធឪពុកម្តាយ ឬអាណាព្យាបាលមិនអោយចូលរួមប្រសិនបើមានហេតុផលសន្និត់ថា ការបដិសេធនោះជាការចាំបាច់ ដើម្បីផលប្រយោជន៍របស់យុវជន ។

សេចក្តីអធិប្បាយ

វិធាន ១៥.១ ប្រើពាក្យស្រដៀងគ្នានឹងពាក្យដែលគេឃើញនៅក្នុងវិធាន ៩៣ នៃបញ្ញត្តិជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងអ្នកទោស ។ ចំណែកឯទីប្រឹក្សាច្បាប់ និងជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃជាការចាំបាច់ ដើម្បីធានា អោយយុវជនបានទទួលការជួយទំនុកបំរុងផ្នែកច្បាប់ ហើយសិទ្ធិរបស់ឪពុកម្តាយ ឬអាណាព្យាបាលដើម្បីចូលរួមក្នុង នីតិវិធីដែលបានថ្លែងរៀបរាប់ក្នុងវិធាន ១៥.២ ត្រូវចាត់ទុកជាជំនួយផ្នែកចិត្តសាស្ត្រ និង ផ្លូវអារម្មណ៍ដល់យុវជន ។ ជំនួយនេះត្រូវមានរហូតនៅក្នុងដំណាក់កាលនៃនីតិវិធី ។

ការខិតខំរកការសំរេចក្តីឱ្យបានសព្វគ្រប់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច អាចបានមកជាពិសេសពីសហប្រតិបត្តិការ របស់អ្នកតំណាងផ្នែកច្បាប់របស់យុវជន (ឬអ្នកជួយផ្ទាល់ខ្លួនដទៃទៀតដែលយុវជនអាចមាន និងទុកចិត្តបានចំពោះរឿង នេះ) ។ ការខិតខំរកដំណោះស្រាយអោយសព្វគ្រប់នេះអាចរលំរលាយទៅវិញប្រសិនបើវត្តមានរបស់ឪពុកម្តាយ ឬ អាណាព្យាបាលនៅក្នុងសវនាការមានតួនាទីជាអវិជ្ជមាន ឧទាហរណ៍ បើអ្នកទាំងនោះបង្ហាញឥរិយាបថជាសត្រូវចំពោះ យុវជន ដូចនេះត្រូវបដិសេធវត្តមានរបស់គេ ។

១៦. របាយការណ៍អំពីប្រវត្តិផ្នែកសង្គម

ក្នុងគ្រប់ករណីទាំងអស់ លើកលែងតែករណីពាក់ព័ន្ធនឹងបទល្មើសតូចតាច មុននឹងអាជ្ញាធរមានសមត្ថកិច្ចចេញ សេចក្តីសំរេចចុងក្រោយបំផុតមុនការផ្តន្ទាទោសប្រវត្តិ និង កាលៈទេសៈដែលយុវជនកំពុងរស់នៅ ឬលក្ខខ័ណ្ឌនៃបទល្មើស ដែលបានប្រព្រឹត្តត្រូវតែបានស៊ើបអង្កេតឱ្យបានត្រឹមត្រូវ ដើម្បីជួយសំរួលការវិនិច្ឆ័យរឿងពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ឱ្យបានត្រឹមត្រូវ ។

សេចក្តីអធិប្បាយ

របាយការណ៍ស៊ើបអង្កេតផ្នែកសង្គម (របាយការណ៍សង្គម ឬរបាយការណ៍មុនការផ្តន្ទាទោស) គឺជាជំនួយខានមិន បាននៅក្នុងនីតិវិធីផ្លូវច្បាប់ភាគច្រើនទាក់ទិននឹងយុវជន ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវដឹងអង្គហេតុទាក់ទងរបស់យុវជន ដូចជាប្រវត្តិសង្គម និងគ្រួសារ ការងារនៅសាលា ការពិសោធន៍ក្នុងការអប់រំ ។ល។ សំរាប់គោលបំណងនេះ យុត្តាធិការ ខ្លះប្រើប្រាស់សេវាកម្មសង្គម ឬ បុគ្គលិកអមតុលាការ ឬ គណៈកម្មការសហគមន៍ ។ បុគ្គលិកដទៃទៀត រួមមានមន្ត្រី ទទួលបន្ទុកការព្យួរទោសអាចបំរើមុខងារនេះដូចគ្នា ។ ដូច្នេះ គោលការណ៍ទូទៅតម្រូវឱ្យត្រៀមសេវាកម្មសង្គម គ្រប់គ្រាន់ សំរាប់ធ្វើរបាយការណ៍ស៊ើបអង្កេតផ្នែកសង្គមដែលមានលក្ខណៈសមស្រប ។

១៧. គោលការណ៍ណែនាំក្នុងការវិនិច្ឆ័យ និងការសំរេចសេចក្តី

១៧.១.ការសំរេចសេចក្តីរបស់អាជ្ញាធរមានសមត្ថកិច្ច ត្រូវយោលទៅតាមគោលការណ៍ដូចតទៅនេះ ៖

(ក) ប្រតិកម្មដែលមានជានិច្ចជាកាល ត្រូវអោយសមាមាត្រនឹងត្រឹមតែនឹងកាលៈទេសៈ និងទំងន់នៃ បទល្មើសប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវឱ្យសមាមាត្រទៅនឹងកាលៈទេសៈ និងសេចក្តីត្រូវការរបស់ យុវជន ព្រមទាំងសង្គមផងដែរ ។

(ខ) ការដាក់កំរិតលើសេរីភាពផ្ទាល់ខ្លួនរបស់យុវជន ត្រូវធ្វើបានបន្ទាប់ពីការពិចារណាហ្មត់ចត់ប៉ុណ្ណោះ ហើយត្រូវកំរិតក្នុងអប្បបរមាដែលអាចធ្វើបាន ។

(គ) សុខមាលភាពរបស់យុវជនជាកត្តានាំមុខក្នុងការពិចារណាករណីរបស់គេ ។

១៧.២. ការផ្តន្ទាទោសប្រហារជីវិតមិនត្រូវលើបទព្រហ្មទណ្ឌណាមួយ ដែលប្រព្រឹត្តដោយយុវជនឡើយ ។

១៧.៣. យុវជនមិនត្រូវទទួលការធ្វើទណ្ឌកម្មលើរូបរាងកាយឡើយ ។

១៧.៤.អាជ្ញាធរមានសមត្ថកិច្ចត្រូវមានអំណាចបញ្ឈប់នីតិវិធីនៅគ្រប់ពេល ។

សេចក្តីអធិប្បាយ

ការលំបាកជាចំបងនៅក្នុងការកំណត់គោលការណ៍សំរាប់ការវិនិច្ឆ័យយុវជនក្មេងលេចចេញមកពីរឿងដែលថា មាន ទំនាស់ផ្នែកទស្សនៈវិជ្ជា ដែលដោះស្រាយមិនចេញដូចជា ៖

(ក) នីតិសម្បទាជាគូនឹងទោសដែលគេសមនឹងទទួល

(ខ) ការជួយឧបត្ថម្ភជាគូនឹងការបង្ក្រាប និងការដាក់ទណ្ឌកម្ម

(គ) ប្រតិកម្មយោងទៅតាមគុណភាពពិសេសនៃករណីនីមួយៗ ជាគូនឹងប្រតិកម្មយោងទៅតាមការការពារ សង្គមទូទៅ ។

(ឃ) ការធ្វើអោយរអាជាទូទៅជាគូនឹងការធ្វើអោយបុគ្គលដែលមានសមត្ថភាពធ្វើអ្វីមួយកើត ។

ទំនាស់រវាងគំនិតទាំងនេះមានច្បាប់នៅក្នុងករណីយុវជនជាងក្នុងករណីមនុស្សពេញវ័យ ។ ដោយមានមូលហេតុ និង ប្រតិកម្មផ្សេងៗគ្នា ដែលសំដែងជានៃករណីរបស់យុវជន ការយកគំនិតមួយទៅជំនួសគំនិតមួយទៀត ក្លាយទៅជា ការចាក់ស្រេះយ៉ាងស្មុគ្រស្មាញ ។

វិធានជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងវិស័យយុត្តិធម៌យុវជន មិនមានមុខងារដាក់កំណត់វិធានណាមួយដែល ត្រូវប្រតិបត្តិតាមទេ ប៉ុន្តែ មានមុខងារចង្អុលបង្ហាញវិធីណាមួយដែលទំនងជាស្របគ្នាច្រើននឹងគោលការណ៍ដែលទទួល យកបានជាអន្តរជាតិ ។ ដូច្នេះ ធាតុផ្សំសំខាន់ដូចបានកំណត់ក្នុងវិធាន ១៧.១ ជាពិសេស ក្នុងអនុកថាខ័ណ្ឌ (ក) និង (គ) ត្រូវបានគេយល់ថាជាគោលការណ៍ណែនាំជាក់ស្តែង ដែលនឹងធានាអោយមានចំណុចចាប់ផ្តើមរួម ។ បើគោលការណ៍ ទាំងនេះត្រូវបានយកចិត្តទុកដាក់ហ្មត់ចត់ពីអាជ្ញាធរដែលពាក់ព័ន្ធ (សូមមើលវិធាន ៥) គោលការណ៍ទាំងនេះរួមចំណែក យ៉ាងសម្បើមក្នុងការធានាថា សិទ្ធិជាមូល

*ដ្ឋានរបស់យុវជនត្រូវបានការពារជាពិសេស សិទ្ធិមូលដ្ឋាននៃការចំរើន លូតលាស់ផ្ទាល់ខ្លួន និង ការអប់រំ ។*

*វិធាន ១៧.១ (ខ) សឱ្យឃើញថា វិធីដោះស្រាយដោយការដាក់ទណ្ឌកម្មមិនមែនជាវិធីសមស្របទេ ។ ចំណែកឯ ក្នុងករណីយុវជនពេញវ័យវិញ ហើយប្រហែលជាក្នុងករណីនៃបទល្មើសធ្ងន់ធ្ងររបស់យុវជនផងដែរ ការចាត់ការទៅតាម ទោសដែលយុវជនសមនឹងទទួល និងការដាក់ទណ្ឌកម្មជាការសងសឹកវិញអាចចាត់ទុកថាជាការគួរមួយដែរ ។ នៅក្នុង ករណីដែលយុវជនការពិចារណាយកវិធីនេះ ត្រូវតែយកជាធំផលប្រយោជន៍ការពារសុខមាលភាព និងអនាគតរបស់ យុវជនក្មេងៗ ។*

*ស្របគ្នានឹងសេចក្តីសំរេចលេខ ៨ នៃសមាជសហប្រជាជាតិលើកទី ៦ វិធាន ១៧.១ (ខ) លើកទឹកចិត្តអោយប្រើ វិធីជំនួសការដាក់ឃុំឃាំងក្នុងស្ថាប័នណាមួយឱ្យបានជាអតិប្បបរមាដែលអាចធ្វើបាន ដោយចាំចងក្នុងចិត្តនូវភាពចាំបាច់ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់លាក់របស់មនុស្សក្មេង ។ ដូច្នេះ ការប្រើវិធីជំនួសដោយពេញទំហឹង ត្រូវធ្វើក្នុង វង្វង់នៃវិធីដាក់ទណ្ឌកម្មជំនួសដែលមាន ហើយត្រូវបង្កើតវិធីដាក់ទណ្ឌកម្មជំនួសថ្មីៗទៀត ដោយចងចាំក្នុងចិត្តនូវសុវត្ថិភាព សាធារណៈ ។ ការដោះលែងតាមបែបសាកល្បង ត្រូវសំរេចឱ្យក្នុងកំរិតធំធេង ដែលអាចធ្វើទៅបានតាមរយៈការព្យួរ ទោសដោយមានលក្ខខ័ណ្ឌបញ្ជារបស់គណៈកម្មការដោះលែង ដោយមានលក្ខខ័ណ្ឌ និងការសំរេចដទៃផ្សេងៗទៀត ។*

*វិធាន ១៧.១ (គ) ត្រូវគ្នានឹងគោលការណ៍មួយនៃគោលការណ៍ណែនាំក្នុងសេចក្តីសំរេចលេខ ៤ នៃសមាជលើក ទី៦ ដែលមានគោលដៅចៀសវាងការដាក់គុកក្នុងករណីយុវជនលើកលែងតែគ្មានការឆ្លើយតបផ្សេងទៀត ដែលសមស្រប ដែលនឹងការពារសុវត្ថិភាពសាធារណៈ ។*

*បញ្ញត្តិដែលហាមប្រាមការផ្តន្ទាទោសដល់ជីវិតក្នុងវិធាន ១៧.២ ស្របគ្នានឹងមាត្រា ៦ កថាខ័ណ្ឌ ៥ នៃកតិកាសញ្ញា អន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។*

*បញ្ញត្តិប្រឆាំងនឹងការដាក់ទណ្ឌកម្មដល់រូបរាងកាយស្របគ្នានឹងមាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ និងសេចក្តីថ្លែងការណ៍ស្តីពីការការពារមនុស្សទាំងអស់ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ បែបអមនុស្សជាតិ ឬដែលនាំអោយបាត់បង់តម្លៃជាមនុស្ស ព្រមទាំងអនុសញ្ញាប្រឆាំងទារុណកម្ម និងការផ្តន្ទាទោស ឬ ការប្រព្រឹត្ត*

ទាំងឡាយដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំអោយបាត់បង់តម្លៃជាមនុស្ស និងសេចក្តីព្រាងអនុសញ្ញា ស្តីពីសិទ្ធិកុមារ ។

អំណាចដើម្បីបញ្ឈប់នីតិវិធីនៅពេលណាមួយ (វិធាន ១៧.៤) គឺជាលក្ខណៈមួយដែលអន្ទោលតាមការចាត់ការ យុវទោសករ គឺផ្ទុយពីការចាត់មនុស្សពេញវ័យ ។ នៅពេលណាមួយកាលៈទេសៈអាចដឹងដល់អាជ្ញាធរមានសមត្ថកិច្ច ដែលនឹងនាំអោយការបញ្ឈប់អន្តរាគមន៍ទាំងស្រុង ទៅជាការសំរេចសេចក្តីល្អបំផុតសំរាប់រឿងរបស់យុវជន ។

១៨. វិធានការផ្សេងៗសំរេចសេចក្តី

១៨.១. វិធានការសំរេចសេចក្តីមួយចំនួនធំ ត្រូវមានសំរាប់អាជ្ញាធរមានសមត្ថកិច្ចប្រើ គឺអាចបត់បែនយកវិធាន ណាមួយប្រើក៏បាន ដើម្បីចៀសវាងការឃុំឃាំងទុកក្នុងស្ថាប័នណាមួយឱ្យបានជាអតិបរមា ដែលអាចធ្វើ ទៅបាន ។ វិធានការបែបនោះដែលខ្លះអាចជាវិធានការរួមបញ្ចូលគ្នារួមមាន ៖

(ក) ការថែទាំការណែនាំផ្លូវ និង បញ្ជាអោយតាមឃ្លាំមើល

(ខ) ការដោះលែងដោយមានលក្ខខ័ណ្ឌ

(គ) បញ្ជាអោយបំពេញសេវាកម្មសំរាប់ប្រយោជន៍សហគមន៍

(ឃ) ការពិន័យផ្នែកហិរញ្ញវត្ថុ ការសងការខូចខាត និងការជួសជុលឡើងវិញ

(ង) ការកែប្រែនៅកំរិតមធ្យមបញ្ជាផ្សេងៗទៀតអោយយកទៅកែប្រែ

(ច) បញ្ជាអោយចូលរួមក្នុងការពិគ្រោះយោបល់ជាក្រុម និងសកម្មភាពស្រដៀងគ្នា

(ឆ) បញ្ជាទាក់ទងនឹងការដាក់អោយនៅជាមួយគ្រួសារផ្សេង សហគមន៍ដែលល្អ ឬបរិយាកាសអប់រំ ដទៃទៀត ។

(ជ) បញ្ជាផ្សេងៗទៀតដែលពាក់ព័ន្ធ ។

18.2> គ្មានយុវជនណាមួយត្រូវបានដកចេញពីការត្រួតពិនិត្យរបស់ឪពុកម្តាយទោះបីមួយផ្នែកក្តី ឬទាំងស្រុង ក្តី លើកលែងតែកាលៈទេសៈនៃករណីរបស់យុវជននោះជាការចាំបាច់ត្រូវធ្វើដូច្នេះ ។

សេចក្តីអធិប្បាយ

វិធាន ១៨.១ ព្យាយាមរៀបរាប់ប្រតិកម្មខ្លះៗនៃប្រតិកម្មសំខាន់ៗ និង ការដាក់ទណ្ឌកម្ម ដែលបានអនុវត្តកន្លងមក ហើយមកទល់ពេលនេះឃើញថាទទួលបានជោគជ័យនៅក្នុងប្រព័ន្ធ ច្បាប់ផ្សេងៗ ។ សរុបមកការទាំងនេះជាមតិល្អៗដែល សមនឹងធ្វើអោយរីកសាយ និងធ្វើអោយ ចំរើនតទៅទៀត ។ វិធាននេះមិនបានរៀបរាប់អំពីលក្ខណៈតំរូវដើម្បីរៀបចំ បុគ្គលិកទេ ព្រោះ មកពីអាចមានការខ្វះខាតបុគ្គលិក មិនគ្រប់គ្រាន់នៅក្នុងតំបន់ខ្លះ ។ តំបន់ទាំងនោះវិធានការ ដែលត្រូវ ការបុគ្គលិកតិចអាចត្រូវបានសាកល្បង ឬបង្កើតឡើងវិញ ។

ឧទាហរណ៍ ដែលផ្តល់ក្នុងវិធាន ១៨.១ មានចំណុចរួមធំបំផុតលើសហគមន៍ការពឹងផ្អែក លើ និងការអំពាវនាវដល់ សហគមន៍ដើម្បីអនុវត្តឱ្យបានប្រសិទ្ធិភាពនូវសេចក្តីសំរេចជំនួសការ ដាក់គុក ។ ការកែប្រែនៅទីកន្លែងសហគមន៍ផ្ទាល់ ជាវិធានការជាប្រពៃណីមួយ ដែលបានចាក់ ឬសក្នុងទិដ្ឋភាពយ៉ាងច្រើន ។ ឈរលើមូលដ្ឋាននេះ អាជ្ញាធរដែលពាក់ព័ន្ធ ត្រូវតែបានលើក ទឹកចិត្តអោយផ្តល់សេវាកម្មនៅសហគមន៍ផ្ទាល់ ។

វិធាន ១៨.២ ចង្អុលបញ្ជាក់សារសំខាន់នៃគ្រួសារដែលតាមមាត្រា ១០ កថាខ័ណ្ឌ ១ នៃ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ គឺជា "ក៏តាធម្មជាតិ និងគ្រឹះនៃ សង្គម " ។ នៅក្នុងគ្រួសារឪពុកម្តាយមិនមែន មានសិទ្ធិប៉ុណ្ណោះទេ ប៉ុន្តែក៏មានការទទួលខុស ត្រូវក្នុងការបីបាច់រក្សា និង ត្រួតពិនិត្យកូនដែរ ។ ដូច្នេះ វិធាន ១៨.២ ដែលតំរូវអោយបំបែកកូន ពីឪពុកម្តាយ គឺជាវិធានការមួយដែលត្រូវធ្វើនៅគ្រាចុងក្រោយបង្អស់ ។ គេអាចពឹងផ្អែកលើ វិធានការនេះតែកាលណាដំណើររឿងអនុញ្ញាតអោយប្រកាន់យកជំហរតឹងរឹងនេះ (ឧទាហរណ៍ ការបំពាបំពានលើ កុមារ) ។

១៩. ការដាក់ក្មេងឱ្យនៅក្នុងស្ថាប័នមួយត្រូវអនុវត្តឱ្យតិចបំផុតដែលអាចធ្វើបាន

១៩.១. ការដាក់យុវជននៅក្នុងស្ថាប័នមួយ ជានិច្ច ជាសេចក្តីសំរេចចុងក្រោយបង្អស់ និង សំរាប់រយៈពេល អប្បបរមាដែលចាំបាច់ប៉ុណ្ណោះ ។

សេចក្តីអធិប្បាយ

ឧក្រិដ្ឋវិទ្យាជឿនលឿន និយមគាំទ្រការកែប្រែនៅក្រៅស្ថាប័នជាជាងការកែប្រែនៅក្នុងស្ថា ប័ន ។ គេសង្កេត ឃើញមានការខុសគ្នាតិចណាស់ ឬគ្មានតែម្តងរវាងជោគជ័យនៃការដាក់យុវ ជនក្នុងស្ថាប័ន និងការដាក់នៅក្រៅស្ថាប័ន ។ ឥទ្ធិពលអវិជ្ជមានជាច្រើនលើបុគ្គលម្នាក់ ដែល

*បាក់ដូចជាមិនអាចចៀសវាងបាននៅក្នុងបរិយាកាសស្ថាប័នដាក់ស្តែងមាន លប់លើកិច្ចប្រឹងប្រែងកែប្រែ ។ ការនេះពិតដូច្នេះ ជាពិសេសក្នុងករណីយុវជនដែលងាយនឹងទទួលឥទ្ធិពលអវិជ្ជមាន ។ ជាងនេះទៅទៀត ផលអវិជ្ជមានមិនត្រឹមតែបណ្តាលមកពីការបាត់បង់សេរីភាពប៉ុណ្ណោះទេ ប៉ុន្តែ ក៏បណ្តាលមកពីការ បែកចេញពីបរិយាកាសធម្មតារបស់សង្គមដែរ ហើយផលអវិជ្ជមានទាំងនេះពិតជាធ្ងន់ធ្ងរសំរាប់យុវជនជាមនុស្សពេញវ័យ ដោយមកពីដំណាក់កាលដំបូងនៃការចំរើនលូតលាស់របស់គេ ។*

*វិធាន ១៩ សំដៅដល់ការដាក់កំរិតលើការដាក់យុវជនក្នុងស្ថាប័នក្នុងទិដ្ឋភាពពីរយ៉ាង ៖ ទៅតាមបរិមាណ ( "វិធាន ការចុងក្រោយបង្អស់ ") និងទៅតាមពេលវេលា ( "រយៈពេលអប្បបរមាដែលចាំបាច់ ") ។ វិធានទី ៩ ឆ្លុះបញ្ចាំង គោលការណ៍មួយនៃគោលការណ៍មូលដ្ឋាននៃសេចក្តីសំរេចលេខ ៤ នៃសមាជលើកទី ៦ នៃអង្គការសហប្រជាជាតិ ៖ យុវទោសករមិនត្រូវដាក់គុកទេ លើកលែងតែគ្មានវិធានការណាផ្សេងទៀតណាដែលសមស្រប ។ ដូច្នេះ វិធាននេះអំពាវនាវថា ប្រសិនបើយុវជនម្នាក់ត្រូវយកទៅដាក់ឃុំឃាំងក្នុងស្ថាប័នមួយ ការបាត់បង់សេរីភាពរបស់យុវជននោះ គួរ ដកហូតក្នុងកំរិតមួយ ដែលតិចបំផុតដែលអាចធ្វើបាន ដោយមានការរៀបចំជាពិសេសសំរាប់ឃុំខ្លួនយុវជន ហើយដោយ ចងចាំក្នុងចិត្តអំពីភាពខុសគ្នាអំពីប្រភេទនៃជនល្មើស បទល្មើស និង ស្ថាប័ន ។ តាមពិតទៅគេត្រូវផ្តល់អាទិភាពដល់ ស្ថាប័ន "ចំហរ " ខ្ពស់ជាងស្ថាប័នដែល "បិទ " ។ តមកទៀតទីកន្លែងឃុំឃាំងនោះត្រូវមានលក្ខណៈជាទីកន្លែងកែប្រែ ឬ អប់រំជាជាងទីកន្លែងដែលមានប្រភេទជាពន្ធនាគារ ។*

*២០. ការចៀសវាងពន្យាពេលមិនចាំបាច់*

*២០.១. ករណីនីមួយៗត្រូវចាត់ការអោយរួសរាន់ ចាប់ពីទីដោយគ្មានការពន្យាពេលដែលមិនចាំបាច់ ។*

*សេចក្តីអធិប្បាយ*

*ការដំណើរការរួសរាន់នៃនីតិវិធីជាផ្លូវការ ក្នុងករណីយុវជនគឺជារឿងដែលត្រូវចាប់អារម្មណ៍ជាទីបំផុត ។ បើពុំ ដូច្នោះទេ ដំណើរការល្អនៃនីតិវិធី និងការសំរេចសេចក្តីអាចនឹងថ្លោះធ្លោយបាន ។ ដោយសារពេលវេលាចេះតែកន្លងទៅ យុវជននឹងស្ថិតក្នុងស្ថានភាពមួយរិតតែលំបាកខ្លាំងឡើង (ប្រសិនបើមិនមែនមិនអាច) ក្នុងការកំណត់ទំនាក់ទំនងនីតិវិធី និង សេចក្តីសំរេចទៅនឹងបទល្មើសទាំងផ្លូវបញ្ញា និងទាំងផ្លូវចិត្តសាស្ត្រ ។*

២១. ការកត់ត្រារឿង

២១.១. ការកត់ត្រារឿងរបស់យុវទោសករ ត្រូវរក្សាទុកជាសំងាត់បំផុត ហើយមិនត្រូវអោយភាគីទីបីដឹងផង ។ សិទ្ធិមើលសេចក្តីកត់ត្រានោះ ត្រូវកំរិតចំពោះតែជនណាដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងសេចក្តីសំរេច រឿងនោះ ឬជនដទៃទៀតដែលបានការអនុញ្ញាតត្រឹមត្រូវ ។

២១.២. ការកត់ត្រារឿងរបស់យុវទោសករ មិនត្រូវយកមកប្រើក្នុងនីតិវិធីសំរាប់មនុស្សពេញវ័យនៅក្នុងករណី ក្រោយៗមកទៀត ដែលពាក់ព័ន្ធនឹងជនល្មើសដដែលទេ ។

សេចក្តីអធិប្បាយ

វិធាននេះព្យាយាមសំរេចបានតុល្យភាពរវាងផលប្រយោជន៍ទំនាស់គ្នាជាប់ទាក់ទងនឹងសេចក្តីកត់ត្រា ឬឯកសារ និងអាជ្ញាធរដទៃទៀត ក្នុងការត្រួតពិនិត្យអោយបានល្អប្រសើរឡើងផ្ទុយនឹងផលប្រយោជន៍របស់យុវទោសករ ។ (សូមមើលវិធានទី ៨ ផងដែរ) ។ ជនដទៃទៀតដែលបានអនុញ្ញាតត្រឹមត្រូវ ៉ ជាទូទៅរួមបញ្ចូលជាអាទិ៍អ្នកស្រាវជ្រាវ ។

២២. ការទាមទារអោយមានភាពជាអ្នកវិជ្ជាជីវៈ និងការហ្វឹកហ្វឺន

២២.១. ការអប់រំវិជ្ជាជីវៈ ការហ្វឹកហ្វឺននៅពេលបំពេញតួនាទីនៅក្នុងក្រសួង វគ្គសិក្សាវិក្រិតការ និងវិធីបង្រៀន ដទៃទៀត ដែលសមស្របត្រូវយកមកប្រើ ដើម្បីបង្កើតនិងថែបំប៉នសមត្ថភាពវិជ្ជាជីវៈដែលចាំបាច់ដល់ បុគ្គលិក ដែលទាក់ទិននឹងករណីយុវជន ។

២២.២. សមាសភាពបុគ្គលិកខាងវិស័យយុត្តិធម៌យុវជន ត្រូវអោយស្របគ្នានឹងភាពចំរុះនៃយុវជន ដែលចូលមក ទាក់ទិននឹងប្រព័ន្ធយុត្តិធម៌យុវជន ។ ត្រូវប្រឹងប្រែងធានាអោយស្ត្រី និងជនជាតិភាគតិចមានតួនាទីជា តំណាងសមរម្យនៅក្នុងទីភ្នាក់ងារខាងវិស័យយុត្តិធម៌យុវជន ។

សេចក្តីអធិប្បាយ

អាជ្ញាធរដែលមានសមត្ថកិច្ចសំរាប់ការសំរេចសេចក្តីអាចជាមនុស្សដែលមានប្រវត្តិខុសៗគ្នា (មន្ត្រីតុលាការនៅក្នុង ចក្រភពអង់គ្លេស និងអៀឡង់ខាងជើង និងក្នុងតំបន់នានាដែលទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់ Common Law ។ ចៅក្រមដែលទទួលការហ្វឹកហ្វឺនខាងច្បាប់ក្នុងប្រទេសដែលប្រើច្បាប់រ៉ូម៉ាំង និង តំបន់ដែលទទួលឥទ្ធិពលពីប្រទេស ទាំងនោះ ។ និងនៅទីកន្លែងផ្សេងទៀត ដែលមានទីប្រឹក្សាប្រជាជន ឬអ្នកច្បាប់ដែលជ្រើសតាំង ឬតែងតាំងសមាជិក របស់គណៈកម្មការសហគមន៍ ។ល។) ។ ចំពោះអាជ្ញាធរទាំងអស់នេះ យ៉ាងហោចបំផុតត្រូវមានការហ្វឹកហ្វឺនខាងច្បាប់ សង្គមវិទ្យា ចិត្តវិទ្យា ឧក្រិដ្ឋវិទ្យា និង វិទ្យាសាស្ត្រខាងប្រតិកម្ម ។ ត្រូវចាត់ទុករឿងនេះជារឿងសំខាន់ ដូចគ្នានឹង ឯកទេសកម្ម នៃអង្គការ និង ឯករាជ្យភាពនៃអាជ្ញាធរមានសមត្ថកិច្ច ។

ចំពោះអ្នកធ្វើការបំរើសង្គម និង មន្ត្រីខាងសំរេចការដោះលែងមានលក្ខខ័ណ្ឌការទាមទារអោយមានឯកទេសកម្ម ជាលក្ខខ័ណ្ឌដំបូងសំរាប់បំពេញមុខងារទាក់ទិននឹងយុវទោសករនោះ គឺប្រហែលជាមិនអាចធ្វើទៅរួចទេ ។ ដូច្នេះ ការ បង្ហាត់បង្រៀននៅពេលកំពុងបំពេញកិច្ចការគឺជាគុណសម្បត្តិទាបបំផុតដែលត្រូវបំពេញ ។

គុណសម្បត្តិខាងវិជ្ជាជីវៈ គឺជាធាតុផ្សំដ៏សំខាន់ក្នុងការធានាការគ្រប់គ្រងដោយឥតលំអៀង និងមានប្រសិទ្ធិភាព ក្នុងវិស័យយុត្តិធម៌យុវជន ។ យោងទៅតាមលក្ខណៈនេះ ចាំបាច់ត្រូវកែលំអរបៀបជ្រើសរើសបុគ្គលិក ការតម្លើងយសសក្តិ និងការហ្វឹកហ្វឺនខាងវិជ្ជាជីវៈដល់ពួកគេ និងចាំបាច់ត្រូវផ្តល់អោយអ្នកទាំងនេះនូវមធ្យោបាយចាំបាច់ ដើម្បីអោយគេអាច បំពេញមុខងាររបស់គេអោយបានត្រឹមត្រូវ ។

ការរើសអើងទាំងអស់ផ្នែកនយោបាយ សង្គម ភេទ ពូជសាសន៍ សាសនា វប្បធម៌ និងប្រភេទរើសអើងដទៃៗ ទៀត នៅក្នុងការជ្រើសរើសការតែងតាំង និង ការតម្លើងយសសក្តិដល់បុគ្គលិកផ្នែកយុត្តិធម៌ យុវជនត្រូវចៀសវាងដើម្បី អោយសំរេចបាននូវភាពមិនលំអៀងក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌យុវជន ។ ការនេះត្រូវបានស្នើឡើងដោយសមាជ លើកទី៦។ ជាងនេះទៅទៀត សមាជលើកទី ៦ អំពាវនាវអោយរដ្ឋជាសមាជិកធានាការ ការចាត់ទុកស្ត្រីអោយបានស្មើ ភាពគ្នា និង ដោយសមរម្យជាបុគ្គលិកសំរាប់វិស័យយុត្តិធម៌ខាងព្រហ្មទណ្ឌ និងបានលើកមតិស្នើអោយប្រកាន់យកវិធាន ការពិសេសៗ ដើម្បីជ្រើសរើស ហ្វឹកហ្វឺន និង ជួយសំរួលការតម្លើង យសសក្តិដល់បុគ្គលិកស្ត្រីភេទនៅក្នុងការគ្រប់គ្រង វិស័យយុត្តិធម៌យុវជន ។

ផ្នែកទី ៤

*ការគ្រប់គ្រងក្រៅស្ថាប័ន*

*២៣. ការអនុវត្តន៍សេចក្ដីសំរេចឱ្យមានប្រសិទ្ធិភាព*

*២៣.១. ត្រូវធ្វើបទបញ្ញត្តិសមស្របសំរាប់អនុវត្តបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ច ដូចបានពោលក្នុងវិធាន ១៤.១ ខាងលើ ដោយអាជ្ញាធរនោះខ្លួនឯងតែម្ដង ឬ ដោយអាជ្ញាធរដទៃទៀតទៅតាមកាលៈទេសៈគួរ ។*

*២៣.២. បទបញ្ញត្តិនោះត្រូវរួមបញ្ចូលអំណាច ដើម្បីកែប្រែបញ្ជាស្រេចតែអាជ្ញាធរមានសមត្ថកិច្ចយល់ឃើញថា ជាការចាំបាច់ទៅតាមពេលវេលា ហើយ ល្គឹកណាតែការកែប្រែនោះធ្វើស្របទៅតាមគោលការណ៍ដែល មាននៅក្នុងវិធាន នានានៃឧបករណ៍នេះ ។*

*សេចក្ដីអធិប្បាយ*

*ការសំរេចសេចក្ដីនៅក្នុងករណីយុវជនមាននិន្នាការជះឥទ្ធិពលលើជីវភាពរបស់ជនល្មើស សំរាប់រយៈពេលយូរជាង ករណីរបស់មនុស្សពេញវ័យ ។ ដូច្នេះ ជាការសំខាន់អាជ្ញាធរមាន សមត្ថកិច្ច ឬអង្គការឯករាជ្យមួយ (គណៈកម្មការ ដោះលែងដោយមានលក្ខខ័ណ្ឌ ការិយាល័យ ដោះលែងសាកល្បងស្ថាប័ន សុខមាលភាពយុវជន ឬ ស្ថាប័នដទៃទៀត) ដែលមានគុណ សម្បត្តិស្មើនឹងអាជ្ញាធរមានសមត្ថកិច្ចដែលសំរេចសេចក្ដីពីដំបូង ត្រូវតាមដានមើលការអនុវត្តន៍ សេចក្ដី សំរេចនោះ ។ នៅប្រទេសខ្លះចៅក្រមអនុវត្តទោសត្រូវបានដាក់ឱ្យបំពេញកិច្ចការនេះ ។*

*សមាសភាពអំណាច និងមុខងាររបស់អាជ្ញាធរត្រឹមតែបត់បែន ។ ទាំងនេះត្រូវបាន ពិពណ៌នាក្នុងន័យទូលំទូលាយ នៅក្នុងវិធាន ២៣ ដើម្បីធានាការទទួលយកបានយ៉ាងទូលំ ទូលាយ ។*

*២៤. ការផ្ដល់ជំនួយដែលត្រូវការ*

*២៤.១. ត្រូវប្រឹងប្រែងផ្ដល់ជំនួយចាំបាច់ដល់យុវជននៅគ្រប់ដំណាក់កាលទាំងអស់នៃ នីតិវិធី ដូចជាទីកន្លែង ស្នាក់នៅ ការអប់រំ ឬការហ្វឹកហ្វឺនវិជ្ជាជីវៈ ការងារ ឬ*

ជំនួយដទៃទៀតដែលមានប្រយោជន៍ និងយកទៅ ប្រើការបាន ដើម្បីជួយសំរួលដំណើរការស្តារនីតិសម្បទាឡើងវិញ ។

សេចក្តីអធិប្បាយ

ការលើកស្ទួយសុខមាលភាពរបស់យុវជន គឺជាការត្រូវពិចារណាអោយបានជិតដល់ ។ ដូច្នេះ វិធាន ២៤ សង្កត់លើ សារៈសំខាន់នៃការផ្តល់កន្លែងសេវាកម្ម និង ជំនួយដទៃទៀតដែលចាំបាច់ ដែលអាចលើកតម្កើងឧត្តមប្រយោជន៍របស់ យុវជននៅក្នុងដំណើរការស្តារនីតិសម្បទាឡើងវិញ ។

២៥. កំណែនអ្នកស្ម័គ្រចិត្ត និង សេវាកម្មដទៃទៀតនៃសហគមន៍

២៥.១. អ្នកស្ម័គ្រចិត្ត អង្គការស្ម័គ្រចិត្ត ស្ថាប័នមូលដ្ឋាន និង ធនធានដទៃទៀតរបស់សហគមន៍ ត្រូវប្រមូលមក ដើម្បីជាវិភាគទានមានប្រសិទ្ធិភាពដើម្បីស្តារនីតិសម្បទាអោយយុវជនឡើងវិញ នៅក្នុងបរិយាកាសមួយ នៃសហគមន៍ ហើយបើអាចធ្វើបាននៅក្នុងចង្កោមគ្រួសារ ។

សេចក្តីអធិប្បាយ

វិធាននេះឆ្លុះបញ្ចាំងសេចក្តីត្រូវការ តំរង់ទិសសំរាប់ស្តារនីតិសម្បទាដល់យុវទោសករនៅគ្រប់កិច្ចការទាំងអស់ ។ សហប្រតិបត្តិការជាមួយសហគមន៍ គឺជាការចាំបាច់ខានមិនបានប្រសិនបើគេត្រូវអនុវត្តសេចក្តីណែនាំរបស់អាជ្ញាធរមាន សមត្ថកិច្ចអោយមានប្រសិទ្ធិភាព ។ អ្នកស្ម័គ្រចិត្ត និង សេវាកម្មស្ម័គ្រចិត្តបានបង្ហាញអោយឃើញថា ជាធនធានដ៏មាន តម្លៃ ប៉ុន្តែនៅពេលនេះគេប្រើមិនទាន់ដល់កំរិតនៅក្នុងពេលខ្លះ សហប្រតិបត្តិការរបស់អតីតជនល្មើស (រួមមានអតីត អ្នកញៀនថ្នាំ) អាចជាជំនួយដ៏ធំ ។

វិធាន ២៥ មានប្រភពចេញមកពីគោលការណ៍ដែលចែងក្នុងវិធាន ១.១ ដល់ ១.៦ និង អនុវត្តតាមបញ្ញត្តិដែល ពាក់ព័ន្ធនៃអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ។

## ផ្នែកទី ៥

## ការគ្រប់គ្រងនៅក្នុងស្ថាប័ន

២៦. គោលដៅនៃការគ្រប់គ្រងក្នុងស្ថាប័ន

២៦.១. គោលដៅនៃការហ្វឹកហ្វឺន និងគ្រប់គ្រងយុវជន ដែលដាក់អោយនៅក្នុងស្ថាប័ន គឺដើម្បីផ្តល់ការថែទាំ ការការពារ ការអប់រំ និងជំនាញខាងវិជ្ជាជីវៈ ក្នុងទស្សនៈជួយពួកគេអោយទទួលយកតួនាទីស្ថាបនា និង មានប្រយោជន៍នៅក្នុងសង្គម ។

២៦.២. យុវជននៅក្នុងស្ថាប័នត្រូវទទួលការថែទាំ ការការពារ និង ការជួយឧបត្ថម្ភទាំងអស់ដែលចាំបាច់ដូចជា ការជួយឧបត្ថម្ភខាងការអប់រំវិជ្ជាជីវៈ ចិត្តសាស្ត្រ ពេទ្យ និងកាយសម្ព័ន្ធ ដែលយុវជនទាំងនោះអាចត្រូវ ការ ព្រោះមកពីអាយុ ភេទ និង បុគ្គលិកលក្ខណៈរបស់គេ និង ក្នុងផលប្រយោជន៍នៃការចំរើន លូតលាស់ទាំងមូលរបស់គេ ។

២៦.៣. យុវជននៅក្នុងស្ថាប័នត្រូវទុកនៅដោយឡែកពីមនុស្សពេញវ័យ ហើយឃុំទុកក្នុងស្ថាប័នដោយឡែកមួយ ឬនៅក្នុងផ្នែកណាមួយដោយឡែកនៃស្ថាប័នដែលដាក់មនុស្សពេញវ័យដែរនោះ ។

២៦.៤. យុវទោសករជានារី ដែលដាក់អោយនៅក្នុងស្ថាប័នមួយសមនឹងទទួលបាននូវការយកចិត្តទុកដាក់ ជាពិសេស ដោយសារសេចក្តីត្រូវការ និង បញ្ហាផ្ទាល់ខ្លួនរបស់គេ ។ ទោះជាក្នុងករណីណាក៏ដោយ គេ មិនត្រូវទទួលការថែទាំ ការការពារ ការជួយឧបត្ថម្ភការគ្រប់គ្រង និងការហ្វឹកហ្វឺនតិចជាងយុវទោសករ ជាបុរសឡើយ ។ ត្រូវធានាអោយមានការគ្រប់គ្រងដ៏សមរម្យសំរាប់អ្នកទាំងនោះ ។

២៦.៥. ក្នុងផលប្រយោជន៍ និង សុខមាលភាពរបស់យុវជន ដែលជាប់នៅក្នុងស្ថាប័នមួយ ឪពុកម្តាយ ឬ អាណាព្យាបាលរបស់គេ ត្រូវមានសិទ្ធិចូលជួបជាមួយគេ ។

២៦.៦. សហប្រតិបត្តិការអន្តរក្រសួង អន្តរមន្ទីរ ត្រូវតែបានជំរុញឱ្យមានក្នុងគោលបំណងផ្តល់ការហ្វឹកហ្វឺនខាង ការសិក្សាគ្រប់គ្រាន់ ឬប្រសិនបើសមស្របការហ្វឹកហ្វឺនវិជ្ជាជីវៈដល់យុវជនដែលជាប់នៅក្នុងស្ថាប័ន ក្នុង ទស្សនៈធានាថា ពួកគេមិនបាត់បង់អត្ថប្រយោជន៍នៃការអប់រំនៅពេលគេចេញពីស្ថាប័ននោះ ។

សេចក្តីអធិប្បាយ

គោលដៅនៃការគ្រប់គ្រងក្នុងស្ថាប័ន ដូចបានចែងក្នុងវិធាន ២៦.១ និង ១៦.២ នឹងអាចទទួលយកបានចំពោះ ប្រព័ន្ធណាមួយ និងសង្គមវប្បធម៌ណាមួយ ។ ក៏ប៉ុន្តែនៅគ្រប់ទីកន្លែងគេ

*មិនបានដល់គោលដៅនេះទេ ហើយមានកិច្ចការ ច្រើនទៀត ដែលត្រូវធ្វើដើម្បីអោយបានសំរេចគោលដៅនេះ ។*

*ការជួយឧបត្ថម្ភផ្នែកពេទ្យ និងចិត្តសាស្ត្រ ជាពិសេសមានសារៈសំខាន់ជាទីបំផុតសំរាប់អ្នកញៀនថ្នាំ មនុស្សក្មេង ហឹង្សា និងវិបត្តិស្មារតីដែលជាប់នៅក្នុងស្ថាប័ន ។*

*ការចៀសវាងឥទ្ធិពលអវិជ្ជមានពីជនល្មើសពេញវ័យ និងវិធានការការពារសុខុមាលភាពរបស់យុវជននៅក្នុងបរិយា កាសនៃស្ថាប័នមួយ ដូចបានចែងក្នុងវិធាន ២៦.៣ គឺស្របនឹងគោលការណ៍មួយនៃគោលការណ៍ណែនាំជាមូលដ្ឋាននៃ វិធានក្រុងប៉េកាំងនេះ ដូចបានកំណត់ដោយសមាជលើកទី៦ ក្នុងសេចក្តីសំរេចលេខ ៤ នៃសមាជ ។ វិធាននេះ មិនរាំង រដ្ឋទាំងឡាយអោយចាត់វិធានការដទៃៗទៀត ប្រឆាំងនឹងឥទ្ធិពលអវិជ្ជមានរបស់ជនល្មើសពេញវ័យទេ គឺរដ្ឋអាចចាត់វិធាន ការយ៉ាងហោចណាស់មានប្រសិទ្ធិភាពដូចវិធានការដែលបញ្ជាក់ក្នុងវិធាននេះដែរ ។(សូមមើលវិធាន ១៣.៤) ។*

*វិធាន ២៦.៤ ឆ្លើយតបចំពោះហេតុដែលចែងថា ជនល្មើសជាស្ត្រីតាមធម្មតា ទទួលការយកចិត្តទុកដាក់តិចជាងជន ល្មើសបុរស ដូចបានគូសបញ្ជាក់ដោយសមាជលើកទី៦ ។ ជាពិសេសសេចក្តីសំរេចលេខ ៩ នៃសមាជលើកទី ៦ អំពាវនាវ សុំអោយមានការគ្រប់គ្រងសមរម្យចំពោះជនល្មើសជាស្ត្រីនៅរាល់ដំណាក់កាល នៃដំណើរការយុត្តិធម៌ខាងព្រហ្មទណ្ឌ និងសុំអោយមានការយកចិត្តទុកដាក់ ជាពិសេសដល់បញ្ហា និងសេចក្តីត្រូវការពិសេសរបស់គេក្នុងពេលជាប់ឃុំឃាំង ។ ជាងនេះទៅទៀត វិធាននេះ ក៏បានពិចារណាស្របតាមសេចក្តីថ្លែងការក្រុងការ៉ាកាស់ នៃសមាជលើកទី ៦ ដែលជាអាទិ៍ អំពាវនាវ សុំអោយមានការគ្រប់គ្រង និងយកចិត្តទុកដាក់ស្មើគ្នានៅក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ និងប្រវត្តិ នៃសេចក្តី ថ្លែងការស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងអនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់ទាំងអស់នៃការរើស អើងប្រឆាំងនឹងស្ត្រី ។*

*សិទ្ធិចូលជួបយុវជន (វិធាន ២៦.៥) ស្របតាមបញ្ញត្តិនៃវិធាន ៧.១, ១០.១, ១៥.២ និង ១៨.២ ។ សហប្រតិបត្តិ ការអន្តរក្រសួង និងអន្តរមន្ទីរ (វិធាន ២៦.៦) មានសារៈសំខាន់ ជាពិសេសក្នុងផលប្រយោជន៍ លើកតំកើងជាទូទៅនូវ គុណភាពនៃការគ្រប់គ្រង និងប្រឹកប្រឹនក្នុងស្ថាប័ន ។*

*២៧. ការអនុវត្តន៍បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោសអនុម័តដោយអង្គការសហប្រជាជាតិ*

*២៧.១ បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស និងអនុសាស្ត្រដែលទាក់ទងនឹងបញ្ញត្តិនេះ ត្រូវ អនុវត្តន៍បានអោយតែទាក់ទង នឹងការគ្រប់គ្រងយុវទោសករ ស្ថិតក្នុងស្ថាប័នរួមមានយុវទោសករ ស្ថិត ក្នុងការឃុំឃាំង ដើម្បីរង់ចាំការវិនិច្ឆ័យ ។*

*២៨.២ ត្រូវប្រឹងប្រែងអនុវត្តន៍គោលការណ៍ដែលទាក់ទង ដែលចែងក្នុងបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់ គ្រប់ គ្រងអ្នកទោសក្នុងកំរិតទូលំទូលាយជាទីបំផុត ដែលអាចធ្វើបាន ដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗ របស់យុវជនស្របតាមអាយុ ភេទ និង បុគ្គលិកលក្ខណៈរបស់គេ ។*

*សេចក្តីអធិប្បាយ*

បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោសស្ថិតក្នុងចំណោមឧបករណ៍ដំបូងដែលមានប្រភេទបែបនេះ ដែលនឹងប្រកាសអោយប្រើដោយសហប្រជាជាតិ ។ មានការព្រមព្រៀងជាទូទៅថា ឧបករណ៍ទាំងនេះមានឥទ្ធិពលទូ ទាំងពិភពលោក ។ ទោះបីជានៅមានប្រទេសដែលមានគំនិតត្រឹមតែចង់អនុវត្តជាងអនុវត្តតែម្តងនោះក៏ដោយ បញ្ញត្តិជា បទដ្ឋានអប្បបរមាទាំងនេះ នៅតែមានឥទ្ធិពលសំខាន់ក្នុងការគ្រប់គ្រង ប្រកបដោយមនុស្សធម៌ និងសមធម៌នូវស្ថាប័ន កែប្រែ ។

*ការការពារសំខាន់ខ្លះដែលគ្របដណ្តប់លើយុវជនទោសករ ជាប់ក្នុងស្ថាប័នដែលមានចែងក្នុងបញ្ញត្តិជាបទដ្ឋានសំរាប់ គ្រប់គ្រងអ្នកទោស (ទីកន្លែងស្នាក់នៅ ស្ថាបត្យកម្ម ប្រដាប់ប្រដាដេក សំលៀកបំពាក់ ការទាមទារ និងសំណូមពរ ការ ជួបជាមួយអ្នកនៅខាងក្រៅ ចំណីអាហារ ការថែទាំខាងពេទ្យ សេវាកម្មសាសនា ការបំបែកការស់នៅពីគ្នាទៅតាមអាយុ ការ រៀបចំបុគ្គលិកការងារ ។ល។) ដូចគ្នានឹងបញ្ញត្តិទាក់ទងនឹងការដាក់ទណ្ឌកម្ម និងការប្រៀនប្រដៅ និងការកំរិតលើ ជនល្មើសប្រកបដោយគ្រោះថ្នាក់ដែរ ។ ជាការមិនសមស្របដែលគេត្រូវកែប្រែបញ្ញត្តិជាបទដ្ឋានអប្បបរមាទាំងនោះ យោលទៅតាមលក្ខណៈពិសេសនៃស្ថាប័នសំរាប់យុវទោសករនៅក្នុងវង្វង់វិសាលភាព នៃវិធានជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងវិស័យយុត្តិធម៌យុវជន ។*

*វិធាន ២៧ ផ្តោតលើលក្ខខ័ណ្ឌតម្រូវចាំបាច់សំរាប់យុវជនជាប់ក្នុងស្ថាប័ន (វិធាន ២៧.១) ព្រមទាំងផ្តោតលើ សេចក្តីត្រូវការផ្សេងៗស្របទៅតាមអាយុ ភេទ និង បុគ្គលិកលក្ខណៈរបស់*

គេ (វិធាន ២៧.២) ។ ដូច្នេះគោលដៅនិង ខ្លឹមសារនៃវិធានការនេះ ទាក់ទងគ្នាទៅវិញទៅមក ជាមួយនឹងបញ្ញត្តិដែលពាក់ព័ន្ធនៃបញ្ញត្តិជាបទដ្ឋានអប្បរបមាសំរាប់ គ្រប់គ្រងអ្នកទោស ។

២៨. ការស្វែងរកជាញឹកញាប់និងដំបូងនៃការដោះលែងដោយមានលក្ខខ័ណ្ឌ

២៨.១ ការដោះលែងដោយមានលក្ខខ័ណ្ឌចេញពីស្ថាប័នមួយ ត្រូវស្វែងរកដោយអាជ្ញាធរសមស្របអោយបាន ជាអតិបរមាដែលអាចធ្វើបាន ហើយការដោះលែងនេះ ត្រូវសំរេចអោយបានដំបូងដៃបំផុតដែលអាចធ្វើបាន។

២៨.២ យុវជនដែលត្រូវបានដោះលែងដោយមានលក្ខខ័ណ្ឌចេញពីស្ថាប័នមួយត្រូវទទួលបានការជួយឧបត្ថម្ភ និង ការត្រួតពិនិត្យដោយអាជ្ញាធរសមស្រប ហើយត្រូវទទួលកិច្ចគាំទ្រពេញទំហឹងពីសហគមន៍ ។

សេចក្តីអធិប្បាយ

អំណាចចេញបញ្ជាអោយដោះលែងដោយមានលក្ខខ័ណ្ឌ ស្ថិតនៅលើអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុង វិធាន ១៤.១ ឬនៅលើអាជ្ញាធរដទៃទៀតខ្លះ ។ ក្នុងទស្សនេះជាការគ្រប់គ្រាន់ដែលគេត្រូវប្រើពាក្យ " សមស្រប " ជា ជាងប្រើពាក្យអាជ្ញាធរ "មានសមត្ថកិច្ច " ។

បើកាលៈទេសៈអនុញ្ញាតអោយ គួរជ្រើសរើយកការដោះលែងដោយមានលក្ខខ័ណ្ឌ ជាជាងការអោយនៅជាប់ទោស នៅក្នុងស្ថាប័នរហូតដល់ចប់ ។ អាស្រ័យលើភស្តុតាងថា មានការជឿនលឿនគួរជាទីពេញចិត្តឆ្ពោះទៅរកនីតិសម្បទា ជនល្មើសអាចដោះដោយមានលក្ខខ័ណ្ឌបាននៅពេលណាដែលអាចធ្វើបាន ទោះបីជាជនល្មើសនោះ ត្រូវចាត់ទុកថា គ្រោះថ្នាក់នៅពេលដាក់ក្នុងស្ថាប័នក៏ដោយ ។ ដូចគ្នានឹងការដោះលែងដោយសាកល្បងដែរ ការដោះលែងមានលក្ខខ័ណ្ឌ នេះ អាចស្រ័យលើការបំពេញលក្ខខ័ណ្ឌតម្រូវគួរជាទីពេញចិត្ត ដែលអាជ្ញាធរពាក់ព័ន្ធបានដៅបញ្ជាក់សំរាប់រយៈពេល មួយសំរាប់ធ្វើការសំរេចចិត្ត ឧទាហរណ៍ ទាក់ទងនឹង " កិរិយាមារយាទល្អ" របស់ជនល្មើសការចូលក្នុងកម្មវិធីបំរើ សហគមន៍ ការអោយនៅក្នុងមជ្ឈមណ្ឌលសំរាប់ហាត់រៀនរស់ឡើងវិញ ។ ល។

ក្នុងករណីជនល្មើសដែលត្រូវបានដោះលែងដោយមានលក្ខខ័ណ្ឌចេញពីស្ថាប័នមួយ ត្រូវផ្តល់ការជួយឧបត្ថម្ភ និង ការត្រួតពិនិត្យមើលពីសំណាក់មន្ត្រីត្រួតមើលការសាកល្បងដោះលែង ឬ មន្ត្រីដទៃទៀត (ជាពិសេសក្នុងករណីមិនទាន់ សំរេចអោយមានការដោះលែងសាកល្បង) ហើយត្រូវមានការលើកទឹកចិត្តអោយមានការគាំទ្រពីសហគមន៍ ។

*២៩. ការរៀបចំអោយមានការគ្រប់គ្រងពាក់កណ្តាលស្ថាប័ន*

*២៩.១ ត្រូវប្រឹងប្រែងធ្វើការរៀបចំអោយមានការគ្រប់គ្រងពាក់កណ្តាលស្ថាប័ន ដូចជា មជ្ឈមណ្ឌលសំរាប់ ហាត់រៀន រស់ឡើងវិញ មជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលហ្វឹកហ្វឺននៅពេលថ្ងៃ និង ទីកន្លែងសមស្រប ដទៃទៀត ដែលអាចជួយអោយយុវជនបានចូលរស់នៅក្នុងសង្គមឡើងវិញដោយត្រឹមត្រូវ ។*

*សេចក្តីអធិប្បាយ*

សារសំខាន់នៃការថែទាំបន្ទាប់ពីរយៈពេលជាប់នៅក្នុងស្ថាប័ន មិនត្រូវមើលស្រាលទេ ។ វិធាននេះសង្កត់លើភាព ចាំបាច់នៃការបង្កើតបណ្តាញទីកន្លែងពាក់កណ្តាលស្ថាប័ន ។

*វិធាននេះ ក៏សង្កត់លើការទាមទារអោយមានទីកន្លែងផ្សេងៗខុសៗគ្នា ដើម្បីអោយស្របតាមសេចក្តីត្រូវការ ផ្សេងៗគ្នានៃយុវទោសករ ដែលចូលមករួមរស់ក្នុងសង្គមឡើងវិញ និង ដើម្បីផ្តល់សេចក្តីណែនាំ និង កិច្ចគាំទ្រអោយបាន សមស្របទៅតាមការផ្លាស់ប្តូរចនាសម្ព័ន្ធសហគមន៍ ដែលជាជំហានសំខាន់ឆ្ពោះទៅរកការរួមរស់ក្នុងសង្គមឡើងវិញ ដោយជោគជ័យ ។*

## ផ្នែកទី ៦

## *ការស្រាវជ្រាវ ការធ្វើផែនការ*
## *ការកំណត់គោលនយោបាយ និង ការវាយតម្លៃ*

*៣០. ការស្រាវជ្រាវជាមូលដ្ឋានសំរាប់ធ្វើផែនការ ការកំណត់គោលនយោបាយនិងការវាយតម្លៃ*

៣០.១ ត្រូវប្រឹងប្រែងរៀបចំ និងលើកស្ទួយការស្រាវជ្រាវចាំបាច់ដើម្បីជាមូលដ្ឋាន សំរាប់ការផែនការ និងការ កំណត់គោលនយោបាយអោយមានប្រសិទ្ធិភាព ។

៣០.២ ត្រូវប្រឹងប្រែងពិនិត្យមើល និងវាយតម្លៃក្នុងរយៈពេលទៀងទាត់នូវនិន្នាការបញ្ហា និងមូលហេតុ នៃយុវ ទោសកម្ម និងឧក្រិដ្ឋកម្ម ព្រមទាំងសេចក្តីត្រូវការសេចក្តីត្រូវការផ្សេងៗណាមួយរបស់យុវជនស្ថិតនៅ ក្នុងការឃុំឃាំង ។

*៣០.៣ ត្រូវប្រឹងប្រែងបង្កើតយន្តការ ការស្រាវជ្រាវទៀតទាត់មួយ ដើម្បីវាយតម្លៃនៅខាងក្នុងប្រព័ន្ធគ្រប់គ្រង វិស័យយុត្តិធម៌យុវជន និងត្រូវប្រមូល និងវិភាគទិន្នន័យ និងពត៌មាន ដែលពាក់ព័ន្ធសំរាប់ការវាយតម្លៃ សមស្រប និងការកែលំអ និងកែទម្រង់ការគ្រប់គ្រងនៅពេលអនាគត ។*

៣០.៤ ត្រូវធ្វើផែនការ និងអនុវត្តដោយមានរបៀបនូវការបំពេញសេវាកម្មនៅក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌ យុវជន ដែលទុកជាផ្នែកផ្សំនៃកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ជាតិ ។

សេចក្តីអធិប្បាយ

ការប្រើការស្រាវជ្រាវជាមូលដ្ឋានសំរាប់គោលនយោបាយយុត្តិធម៌យុវជន ដែលផ្អែកលើពត៌មានដែលប្រមូលបាន ត្រូវបានទទួលស្គាល់ជាទូទៅថា ជាយន្តការសំខាន់មួយធ្វើអោយការអនុវត្តដើរទាន់ការជឿនលឿនខាងចំណេះដឹង និង ការអភិវឌ្ឍន៍កំពុងប្រព្រឹត្តទៅ និងការកែលំអប្រព័ន្ធយុត្តិធម៌យុវជន ។ ការផ្តល់ពត៌មានទៅវិញទៅមករវាងការស្រាវ ជ្រាវ និងគោលនយោបាយមានសារសំខាន់ ពិសេសនៅក្នុងយុត្តិធម៌យុវជន ។ ដោយមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងញឹកញាប់នៅក្នុងរបៀបរស់នៅរបស់ក្មេងៗ និងនៅក្នុងទម្រង់ និងទំហំនៃឧក្រិដ្ឋកម្មយុវជន ការឆ្លើយតបផ្នែកសង្គម និងយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មយុវជន និងយុវទោសកម្មក្លាយទៅជាការហួសសម័យយ៉ាងឆាប់សហ័ស និងមិនគ្រប់គ្រាន់ ដែរ ។

ដូច្នេះ វិធាន ៣០ កំណត់បទដ្ឋានសំរាប់រួមបញ្ចូលការស្រាវជ្រាវទៅក្នុងដំណើរនៃការកំណត់គោលនយោបាយ និង ការអនុវត្តនៅក្នុងការគ្រប់គ្រងយុត្តិធម៌យុវជន ។ វិធាននេះ ទាញយកការយកចិត្តទុកដាក់ ជាពិសេសចំពោះការទាមទារ អោយមានការពិនិត្យសារឡើងវិញ និងការវាយតម្លៃជាប្រក្រតី នូវកម្មវិធី និងវិធានការដែលមានមកហើយ និងការ ទាមទារអោយមានការធ្វើផែនការនៅក្នុងបរិបទទូលំទូលាយនៃគោលដៅអភិវឌ្ឍន៍ទាំងមូល ។

ការវាយតម្លៃជាប្រចាំនូវសេចក្តីត្រូវការរបស់យុវជន ព្រមទាំងនិន្នការ និងបញ្ហាទោសកម្មជាការទាមទារមុនគេ សំរាប់កែលំអវិធីកំណត់គោលនយោបាយសមស្រប និងសំរាប់កំណត់ការធ្វើអន្តរាគមន៍គ្រប់គ្រាន់ក្នុងកំរិតផ្លូវការ និង ក្រៅផ្លូវការ ។ ក្នុងន័យនេះ ការស្រាវជ្រាវដោយមនុស្ស និងអង្គការឯករាជ្យ ត្រូវតែបានជួយសំរួលដោយទីភ្នាក់ងារ ដែលទទួលខុសត្រូវ ហើយការស្រាវជ្រាវនេះ អាចមានតម្លៃបើបាន និងយកចិត្តទុកដាក់លើទស្សនៈរបស់យុវជនទាំងឡាយ មិនត្រឹមយុវជនដែលមានបញ្ហាជាមួយប្រព័ន្ធយុត្តិធម៌ប៉ុណ្ណោះទេ ។

ដំណើរការធ្វើផែនការត្រូវសង្កត់ជាពិសេសលើប្រព័ន្ធមានប្រសិទ្ធិភាព និងសមធម៌ខ្ពស់សំរាប់ការបំពេញសេវាកម្ម ចាំបាច់ ។ ឆ្ពោះទៅរកគោលដៅនេះ ត្រូវមានការវាយតម្លៃទូលំទូលាយជាប្រក្រតីនូវសេចក្តីត្រូវការ និងបញ្ហាពិសេសៗ និងទូលំទូលាយរបស់យុវជន និងត្រូវ

*រកអោយឃើញអាទិភាពច្បាស់ៗ ។ ក្នុងន័យនេះ ក៏ត្រូវមានការសំរបសំរួលនៅក្នុង ការប្រើធនធានដែលមានដៃររួមមាន មធ្យោបាយជំនួស និងកិច្ចគាំទ្ររបស់សហគមន៍ ដែលសមស្រប ក្នុងការបង្កើតនីតិ វិធីជាក់លាក់ដើម្បីអនុវត្ត និងតាមឃ្លាំមើលកម្មវិធីដែលបានបង្កើតមក ។*